# ជំពូក 13 ការស្រោចស្រព និង ដោះទឹក

## 13.1 ការពិនិត្យមើលគំនិតគ្រោង នៃប្រពន្ធ័សំណង់ដែលមានស្រាប់

### 13.1.1 ការពិនិត្យមើលប្រវត្តិគំរោង

សំរាប់ប្រពន្ធ័ស្រោចស្រពដែលមានស្រាប់យ៉ាងច្រើន ជាពិសេសសំរាប់ប្រពន្ធ័ដែលបានសាងសង់ក្នុងរបបប៉ុលពត ឯកសារ និង គំនូរប្លង់មួយចំនួននៃផែនការស្រោចស្រព ហើយគំរោងដែលអាចរកបានក្នុងពេលបច្ចុប្បន្ន។ ទោះយ៉ាងនេះក្តី វាមានការលំបាកក្នុងការដណ្តើមយកគំនិតនៃប្លង់ដើម និង គ្រោងសំណង់ដែលមានស្រាប់។ សំរាប់ផែនការស្តារ និង ជួសជុលឡើងវិញនៃប្រព័ន្ធស្រោចស្រពដែលមានស្រាប់ វាជាតំរូវការចាំបាច់ក្នុងការដណ្តើមយកនូវលក្ខណៈនៃប្រព័ន្ធក្នុងការចាប់ផ្តើមការងារជាបន្ទាន់ ។ គោលប្លង់ដើម គំរូប្លង់គ្រោង និង មូលដ្ឋានពត៌មានសំរាប់ប្លង់គ្រោង គួរតែផ្តល់របាយការណ៍រាល់ទីតាំងពិតប្រាកដ ។ ការវាស់ស្ទង់ និង សំភាសន៍ត្រូវបានប្រើគ្រប់សំណង់ពីពេលមុន ។

តាមពត៌មានបានបង្ហាញបញ្ជាក់ពិត ប្រាកដគួរតែបានបង្រួញតាមរយៈផែនការ :

- គោលនៃប្លង់ដើម
  - ប៉ានលេខា ភូគព្ភសាស្ត្រ និង គំនូសព្រាងនៃប្រព័ន្ធស្រោចស្រពដែលមានស្រាប់
  - ការអនុវត្តទឹកសិដ្ឋាន និង បែបបទដំណាំ នៃផ្ទៃដីដែលបានស្នើរឡើង
  - គោលនៃប្លង់ស្រោចស្រពដើម ( ផ្ទៃដីស្រោចស្រព សំណង់សំរាប់ស្រោចស្រព ។ល។ )
- ស្ថានភាពនៃភូគព្ភសាស្ត្រ និង ប៉ានលេខា (ផែនទី ជំរេល សម្ពាធ ទន្លេ ឬ ស្ទឹង បង្ហូរ ទីដីខ្ពស់ (ដីចំការ)) ។
- ដីប្រើប្រាស់ និង ផ្ទៃដីដែលត្រូវលើកឡើង
- ឧតុនិយម និង ជលសាស្ត្រ
- សមត្ថភាព និង មុខងារនៃសំណង់ស្រោចស្រពដែលមានស្រាប់
- គំរូគ្រោងប្លង់

### 13.1.2 ការពិចារណាពិសេសលើប្រព័ន្ធដែលមានស្រាប់

ប្រតិបត្តិតាមដំណោះស្រាយនៃការសិក្សា បញ្ហាបច្ចេកទេសជាច្រើនដែលបានរកឃើញលើសំណង់ដែលមានស្រាប់ ។ បញ្ហាមួយចំនួនមិនអាចដោះស្រាយដោយការស្តារ និង ជួសជុលឡើងវិញនៃសំណង់ដើម ។ តាមបញ្ហានេះគួរតែត្រួតពិនិត្យឱ្យបានទាន់ពេលលើសំណង់ដែលមានស្រាប់ ។

(1) **ខ្សែប្រឡាយ** (Route of Canal)

ក្នុងករណីខ្លះប្រឡាយដែលមានស្រាប់ មានទីតាំងក្នុងស្ថានភាពគុណវិបត្តិដែលផ្នែកភាគច្រើននៃប្រឡាយដែលត្រូវបានសាងសង់ដោយការជីក ។ ក្នុងប្រទេសកម្ពុជាបានហៅដូចនេះថា "ខួរអណ្តែង" មានភាពគ្របដណ្តប់ពីលើ ។ សំណង់អំពីដីដែលជាដីខួរអណ្តែងមានភាពងាយស្រួលពេលដែលដីបានបង្ហាញ

ពីកំរិតខ្ពស់នៃវត្ថុមានទឹក ។ ភ្លឺប្រឡាយគួរតែបានសំរេចចិត្តពិតប្រាកដដោយសមគួរ ដូច្នេះតុល្យភាពមុខកាត់ត្រូវថែទាំ និង ការជីកជំរៅបានរក្សាទុកមិនឱ្យលើស 2 ម. ។ ប្រសិនភ្លឺដើមមិនបានធ្វើឱ្យពេញចិត្តតាមតំរូវការ ជំរើសភ្លឺនៃ ប្រឡាយគួរតែបានពិចារណា ។

**(2) សំភារៈសំរាប់សាងសង់ភ្លឺ**

សំរាប់អាងទឹក និង ទំនប់ជាច្រើន សំភារៈក្នុងស្រុកសំរាប់ធ្វើការសាងសង់នៅការដ្ឋានត្រូវបានប្រើប្រាស់ដោយគ្មានការប្រព្រឹត្តត្រឹមត្រូវ ។ ដូចបានអធិប្បាយខាងលើ ដីខ្សាច់ និង ការស្ដារដី មិនសមគួរសំរាប់ភ្លឺ ហើយសំភារៈចាំបាច់ដូចជាដីក្រហមគួរតែបានប្រើប្រាស់ ។ ការការពារទំនប់ដូចជារៀបថ្មស្ងួតតាមជើងទេរក៏ចាំបាច់ផងដែរ ។ ដូច្នេះទឹកន្លែង និង មាឌនៃសំភារៈសំរាប់ការសាងសង់សំរាប់ភ្លឺគួរមានភាពប្រុងប្រយ័ត្នក្នុងការពិនិត្យពិច្ច័យ ។

**(3) សំណង់បង្ហៀររបស់អាងទឹក**

អាងទឹកជាច្រើនបាត់បង់មុខងារចាប់តាំងពីទំនប់បាក់ធ្លាយ ។ ហេតុផលចម្បងនៃការបាក់ធ្លាយមាន : i) គ្មានសំណង់បង្ហៀរ ii) កង្វះខាតទ្វារទឹក (Slop log) iii) កង្វះខាតសំភារៈសំរាប់សាងសង់ភ្លឺ iv) ជំរេលជើងទេររបស់ ភ្លឺ ( ទំនប់ ) មិនគ្រប់ គ្រាន់ v) កង្វះខាតក្នុងការការពារភ្លឺ ( ទំនប់ ) និង សំណង់ ។ល។

ដូច្នេះប្រភេទសំណង់សំរាប់បង្ហូរទឹកចេញដែលត្រូវការការថែទាំបន្តិចបន្តួច ហើយដែលប្រតិបត្តិការគួរតែត្រូវបានកសាងឡើង ហើយនិងសំណង់បង្ហៀរដែលធ្វើប្រតិបត្តិការ គួរតែមានទ្វារទឹកដ៏ល្អដើម្បីបង្ហាញឱ្យដឹងនៅក្នុងអំឡុងពេលដែលមានទឹកជំនន់ ។

**(4) សំណង់ឆ្លងកាត់ប្រឡាយ**

ក្នុងករណីជាច្រើន សមត្ថភាពនៃសំណង់ឆ្លងកាត់លើប្រឡាយ ( ស្ពាន លូបង្ហូរទឹកឆ្លងកាត់ទទឹងប្រឡាយ លូទឹកកាត់ភ្លឺ ទសំរាប់បង្ហូរទឹកជាដើម ។ល។ ) ដែលមិនគ្រប់គ្រាន់ ហើយទឹកជំនន់កន្លងមកជារឿយៗបានបំផ្លាញប្រឡាយដោយខ្លួនវា ។ ដូចនេះសមត្ថភាពនៃសំណង់ឆ្លងកាត់ គួរតែបានត្រួតពិនិត្យឡើងវិញឱ្យបានសមរម្យ ។

**(5) សមត្ថភាពនៃប្រឡាយដែលមានស្រោប់**

ប្រឡាយដែលមានស្រោប់បានប្រើប្រាស់មិនសំរាប់តែការស្រោចស្រពប៉ុណ្ណោះទេ ប៉ុន្តែគឺសំរាប់ដោះទឹកចេញផងដែរ ។ ដូច្នេះសំណើរសមត្ថភាពរបស់ប្រឡាយគួរតែសំរេចចិត្តពិតប្រាកដក្នុងការដាក់បញ្ចូលក្នុងគោលបំណងរួមគ្នាតែមួយ ។

## 13.2 កំរិតគោលដៅនៃការស្ដារ និង ជួសជុលឡើងវិញ

កំរិតគោលដៅនៃការស្ដារ និង ជួសជុលឡើងវិញ ការស្រោចស្រព និង ប្រព័ន្ធដោះទឹកគឺបានរៀបរាប់សេចក្ដីសរុបតាមតារាង 13.1 ដូចខាងក្រោម :

### 13.2.1 ផែនការការស្រោចស្រព

#### (1) វិធីសាស្ត្រការស្រោចស្រព

តាមរយៈការស្រោចស្រពស្រូវ " វិធីសាស្ត្រការស្រោចស្រពដោយស្រះទឹក " និង " វិធីសាស្ត្រសន្សំសំចៃទឹក" ត្រូវបានពិចារណា ។ ក្នុងករណីនេះមានន័យថា ធនធានទឹកមិនបានគ្រប់គ្រាន់សំរាប់វិធីសាស្ត្រការស្រោចស្រពដោយប្រើប្រាស់ទឹកនោះទេ វិធីសាស្ត្រការស្រោចស្រពដោយសន្សំសំចៃទឹកគួរបានផ្លាស់ប្តូរសំរាប់ស្រូវ ដូច្នេះធនធានទឹកត្រូវបានកំណត់ក្នុងការសន្សំសំចៃ ។ ការស្រោចស្រពផ្លាស់ប្តូរសារចុះសារឡើងសំរាប់ក្រុមប្រឡាយស្រោចស្រព ។ ប្រឡាយមេ និង ប្រឡាយស្រោចស្រព គួរប្រើប្រាស់បានរយះពេល 24 ម៉ោង ហើយកំរិតកំពស់ទឹកគួរបានថែរក្សាដោយសំណង់ត្រួតពិនិត្យ ។ គោលគំនិតនៃវិធីសាស្ត្រការស្រោចស្រពបានអធិប្បាយក្នុងផ្នែកចម្បង 13.4.1 "ការអនុវត្តន៍ប្រព័ន្ធទីវាល " ( Field application System ) វិធីដំណើរការនៃការប៉ាន់ស្មានតំរូវការទឹកបានអធិប្បាយក្នុងផ្នែកចម្បង 13.4.2 " តំរូវការទឹក ការស្រោចស្រពសុទ្ធ " ។

#### (2) ភាពទុកចិត្តបាន

ភាពទុកចិត្តបាន 80% ឬ 4 ក្នុងរយះពេល 5 ឆ្នាំ គឺបានរក្សារទុកជារបស់ខ្លួនតាមភាពទុកចិត្តបាននៃប្រព័ន្ធស្រោចស្រព ។ ក្នុងភាពដែលអាចប្រព្រឹត្តទៅបាននេះ សំណើ នៃផ្ទៃដីស្រោចស្រពដែលស្រោចស្រពបានតាមសំណើ បរិមាណទឹក 80% នៃភាពទុកចិត្តបាន ។

### 13.2.2 សំណង់សំរាប់ស្រោចស្រព

#### (1) អាងទឹក

1) ការគ្រោងទឹកជំនន់

ការគ្រោងទឹកជំនន់នៃអាងទឹកគួរអោយបានសមស្របតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម

តារាង ការគ្រោងទឹកជំនន់

| លក្ខណៈសម្បត្តិនៃអាងទឹក | កំរិតគោលដៅនៃការអភិវឌ្ឍន៍. |
|---|---|
| ការគ្រោងទឹកជំនន់សំរាប់សំណង់បង្ហូរលើទឹកស្ទឹងគ្រប់ឆ្នាំ ( រាល់កាល គ្រប់កាល ) | រយៈពេលទឹកជំនន់ដែលមានឡើងវិញក្នុង 100ឆ្នាំ ឬ ទឹកជំនន់ធំបំផុតក្នុងអតីតកាល ( បានប៉ាន់ស្មានដោយតាមដាន និង សំភារៈអ្នកមានលំនៅជាប់លាប់ក្នុងបរិវេណនោះ ) ទោះយូរ យ៉ាងណាក៏ដោយ ។ |
| ការគ្រោងទឹកជំនន់សំរាប់អាងទឹកខ្នាតតូចដែលផ្ទៃរងទឹកភ្លៀងតូចជាង 10 $Km^2$ ឬសមត្ថភាពនៃការរក្សាទឹកសរុប តិចជាង 50,000 $m^3$ | រយៈពេលទឹកជំនន់ដែលមានឡើងក្នុង 20 ឆ្នាំ |

វិធីដំណើរការនៃការប៉ាន់ស្មានការគ្រោងទឹកជំនន់ ត្រូវបានអធិប្បាយយ៉ាងលំអិតក្នុងផ្នែក 11.2 " ទឹកជំនន់ " ។

2) ទំនប់

ទំនប់នៃអាងទឹកគួរបានសាងសង់ឡើងដោយវត្ថុធាតុដើមគឺដី ។ កំពស់ខ្ពស់បំផុតទំនប់គួរតែកំណត់ត្រឹម 5 ម. ជាគោល ដូចនេះជាភាពរឹងមាំដែលបានថែទាំទំនប់ ។ ប្រសិនមានកំពស់ខ្ពស់ជាង 5 ម ការវិភាគលើភាពរឹងមាំនៃទំនប់គួរបានប្រតិបត្តិ ។ សំភារៈក្នុងស្រុកនៅជិតទឹកន្លែងដែលបានស្នើរអាច

ប្រើប្រាស់បានប្រសិនបើសំភារៈទាំងនេះគ្មានលាយខ្សាច់ (ដីខ្សាច់) ឬ មានចរិតលក្ខណៈនៃការបែកខ្ញែកគ្នារបស់ដី ។ ផ្នែកជើងទេរនៃអាងទឹកគួរបានការពារជាមួយសំភារៈមិនជ្រាបទឹក និង រៀបថ្ម ។

គំរូពំនុះកាត់នៃទំនប់បានបង្ហាញក្នុងរូបភាព 13.1 ក្នុងករណីនេះសំភារៈមិនជ្រាបទឹកមិនគួរបានប្រើប្រាស់ ជើងទេរទំនប់គួរបានប្តូរឱ្យស្រាល ដូច្នេះភាពរឹងមាំនៃទំនប់គឺមាំមួន ។ ដូចក្នុងរូបភាព 13.2 បញ្ជាក់ស្រាប់ ។

3) **សំណង់បង្ហូរទឹកចូល**

សំណង់បង្ហូរទឹកចូលប្រកបឡើងដោយទ្វារធ្វើការជាប្រចាំ ។ ទំហំទ្វារគួរធ្វើឱ្យរឹងមាំ ដូច្នេះធ្វើឱ្យស៊ាំនឹងភាពរឹងមាំ ។ កំរិតមេនៃទ្វារគួរដាក់កំរិតដែលបានធ្វើការប៉ាន់ស្មានកំរិតរក្សាទឹកច្បាស់លាស់ក្រោយ 20ឆ្នាំ ការធ្វើការកំរិតកំពស់ទឹកនៃអាងទឹកគឺបានអធិប្បាយក្នុងផ្នែក 13.5 ។

4) **សំណង់បង្ហៀរ**

បែបផែនហូរពីលើសំណង់បង្ហៀរទឹក មានភាពងាយស្រួលដល់ការបង្ហូរទឹកបានរហ័សនៃទឹកជំនន់ដោយមិនភ្លាត់ក្នុងការកាត់បន្ថយទឹកចេញ ។ ក្នុងករណីនេះការគ្រោងក្នុងការកាត់បន្ថយទឹកជំនន់ដែលធំខុសពីធម្មតាពេលដែលផ្ទៃរងទឹកភ្លៀងធំ ការធ្វើការងារនៃសំណង់បង្ហៀរទឹក និង សំណង់បង្ហៀរទឹកជាបន្ទាន់ត្រូវបានធ្វើឡើងដោយឡែកពីគ្នា ។ ចាប់តាំងពីតំលៃនៃសំណង់បង្ហៀរទឹកជាផ្នែកដ៏ធំដែលមាននៅក្នុងតំលៃសរុបនៃសំណង់ ប្រភេទសំណង់សាមញ្ញជាមួយសំភារៈក្នុងស្រុកត្រូវបានទទួលការត្រួតពិនិត្យ ៍ ។ សំណង់បង្ហូរទឹកចេញមួយដែលបានធ្វើការសាងសង់ជិតសំណង់ហូរទឹកពីលើសំណង់បង្ហៀរទឹក ដូច្នេះកំរិតកំពស់ទឹកក្នុងអាងបានធ្វើការត្រួតពិនិត្យ ទោះបីកំរិតផ្តល់ឱ្យស្មើ ឬ ទាបជាង និងរក្សាការកាត់បន្ថយបាននៃរំហូររបស់ស្ទឹង ។

5) **ចន្លោះសេរី**

ចន្លោះសេរីនៃអាងទឹកមួយជាមូលដ្ឋានមិនឱ្យលើសពី 0.90 ម. (ពីកំរិតកំពស់ទឹកជំនន់ដល់កំរិតកំពស់ខ្នងទំនប់) ។ សំរាប់អាងទឹកខ្នាតតូចដែលផ្ទៃរងទឹកភ្លៀងតូចជាង 10 គម² ឬ សមត្ថភាពនៃការរក្សាទឹក ទុកតិចជាង 50,000 ម³. ចន្លោះសេរីដែលអាចទទួលយកបានគឺ 0.60 ម. ។

6) **កករល្បាប់**

កករល្បាប់ក្នុងអាង គួរបានប៉ាន់ស្មានសំរាប់កំរិតទឹកក្នុងអាងមិនអាចប្រើប្រាស់ពិតប្រាកដនៃសមត្ថភាពរក្សាទឹកទុក ។ គំរូនៃអត្រាចំនួនកករល្បាប់ 0.1មម. /គម²/1ឆ្នាំ ដែលអាចប្រើប្រាស់បានសំរាប់ការប៉ាន់ស្មាននៃមាឌកករល្បាប់ ។ កំរិតកករល្បាប់ក្រោយរយៈពេល 20 ឆ្នាំ ដែលអាចទទួលយកបានគឺ "កំរិតកំពស់ទឹកទាប" ដែលស្មើនឹងកំរិតកំពស់ទឹកហូរចេញ ។

(2) **ប្រឡាយ**

1) **ប្រឡាយមិនប្រើប្រាស់ និង ប្លុកស្រោចស្រព**

ប្រឡាយជាច្រើនរួមមានប្រឡាយមេ ប្រឡាយរង ប្រឡាយស្រោចស្រព និង ផ្លូវទឹក ។ ប្រឡាយមេ និង ប្រឡាយរងត្រូវមានសំណង់ទ្វារទឹកត្រួតពិនិត្យ ហើយសំណង់ទ្វារទឹក បង្វែរទឹកដែលអាចកាត់បន្ថយបានក្នុងការត្រួតពិនិត្យ ។

ការហូរចេញទៅកាន់ប្លុកប្រឡាយស្រោចស្រពត្រូវមានសំណង់ត្រួតពិនិត្យផងដែរ (ទ្វារទឹក ឬ ស្ទាក់ទឹក ) ហើយទ្វារហូរទឹកចូលពិនិត្យដោយចរន្ត ទឹកហូរ ។ ផ្ទៃនៃប្លុកប្រឡាយស្រោចស្រព ប្រមាណ 50 ហិចតា ដែលរួមទាំងទីតាំងភូមិផង ។ ប្រវែងបណ្តោយប្រឡាយស្រោចស្រពមិនអោយលើសពី 1 គ.ម ។ ការបង្វែរទឹកពីប្រឡាយស្រោចស្រពទៅកាន់ផ្លូវទឹកមិនបានត្រួតពិនិត្យបើគ្មានសំណង់ទ្វារទឹក ។ ប្រឡាយស្រោចស្រព និង ផ្លូវទឹកគួរមានសមត្ថភាពគ្រប់គ្រាន់នៃការប្រកាន់យកការស្រោចស្រពសារចុះសារឡើងទៅក្នុងបញ្ជី ។

2) **ស្រទាប់ខាងក្នុង**

សេចក្តីចាំបាច់នៃស្រទាប់ខាងក្នុង គួរបានពិភាក្សាជាមូលដ្ឋានពីចរិកលក្ខណៈរបស់ដីនៃការកាត់ជាចំណែកនូវសំភារៈរបស់ភ្លឺ (ភ្លឺប្រឡាយ) ។ សំរាប់ស្រទាប់ខាងក្នុងដីស្រទាប់ក្នុង ដែលការជ្រើសរើសជាបឋមជាមួយនឹងមេគុណភាពគគ្រាត " Manning " គឺ 0.025[2] ។ ក្នុងករណីនេះការគ្រោងល្បឿនមិនអាចថែរក្សាបានស្រទាប់ខាងក្នុងជាមួយស៊ីម៉ង់ត៍ដី បន្ទះបេតុង ហើយនឹងបេតុងដែលលាយឯទីកន្លែងនោះផ្ទាល់គួរបានត្រួតពិនិត្យ ។ សំរាប់ប្រឡាយដែលរត់ឆ្លងកាត់ផ្ទៃនៃដីខ្សាច់ត្រូវប្រើដីមិនជ្រាបទឹកដាក់ជាទ្រនាប់ដោយត្រឹមត្រូវ ឬ សំភារៈប្រើសំរាប់ស្រទាប់ខាងក្នុងផ្សេងៗទៀត ។ ជាតួយ៉ាង ផ្នែកខ្លះនៃប្រឡាយបង្ហាញរូបភាព 13.3 ។ វាគប្បីសំគាល់បានថាការដាក់ ទ្រនាប់ដីនៃប្រឡាយជាសេចក្តីត្រូវការធ្វើការថែរក្សាខួបដោយយកចេញកំទេចឈើ និង កករល្បាប់ក្នុងផ្នែកនៃប្រឡាយដែលត្រូវបានធ្វើឡើងដោយសហគមន៍កសិករប្រើប្រាស់ទឹក (FWUC) ។ ការបង្ហាញពីចំនុចផ្សេងៗទៀត ស្រទាប់ខាងក្នុងនៃប្រឡាយត្រូវអោយស្រាលដែលជាបន្ទុកដីធ្ងន់លើការថែរក្សាខួបរបស់សហគមន៍កសិករប្រើប្រាស់ទឹក (FWUC) ។ វាមានន័យថាស្រទាប់ខាងក្នុង នឹងកើនឡើងនូវការបង្រួញតំលៃ ប្រាក់ជាដើមទុន ប៉ុន្តែតំលៃថែទាំថយចុះ ។

3) **ការប្រើប្រាស់ជាប្រយោជន៍នីសមត្ថភាពមានស្រាប់**

ជាអត្ថិភាពនៃការស្តារ និង ជួសជុលឡើងវិញនូវប្រឡាយគួរបានផ្តល់ទៅអោយ "សេចក្តីត្រូវការបានមកដោយរំហូរទឹកក្នុងប្រឡាយ" ។ ក្នុងបញ្ហានេះផ្នែកប្រឡាយមានស្រាប់អាចប្រើប្រាស់ជាប្រយោជន៍បានដោយធ្វើឱ្យមានជីតិចបំផុត ។ ក្នុងករណីនេះចំនួនភាពគគ្រាតធំបំផុតគឺ 0.035 (ប្រសិនផ្នែកដែលមានស្រាប់ពេញដោយភាពប្រើប្រាស់ជាប្រយោជន៍) ឬ 0.030 (ប្រសិនផ្នែកដែល

មានស្រាប់ប្រើប្រាស់បានផ្នែកខ្លះៗ) គួររក្សាទុកបាន ។ ការបង្ហាញដោយរូបភាពលំអិតក្នុងរូបភាព 13.4 ប្រសិនប្រឡាយដែលមានស្រាប់ប្រើប្រាស់បានពេញលេញ (ចំនុចចាប់ផ្តើមទៅកាន់ចំនុចបញ្ចប់) សមត្ថភាព និង កំរិតកំពស់ទឹកក្នុងប្រឡាយគួរតែត្រួតពិនិត្យបានដោយគ្មានវិភាគវំហូរជាឯកសណ្ឋាន ។

4) **ចន្លោះសេរី**

បានដាក់បញ្ចូលក្នុងការគណនាចលនានៃផ្ទៃទឹកដោយទឹកឡើង ។ល។ ចន្លោះសេរីពិតប្រាកដគួរយកទៅបាន ។ ជំរៅនៃចន្លោះសេរីបានអធិប្បាយក្នុងផ្នែកចម្បង 13.6.7 " ការគ្រោងជាបឋមនៃប្រព័ន្ធប្រឡាយ " ។

5) **ការប្រើប្រាស់រួមគ្នានៃប្រឡាយ**

ប្រឡាយស្រោចស្រពដែលបានគ្រោងជាអាទិ ដើម្បីមានសមត្ថភាពសំរាប់ទឹកស្រោចស្រព ។ ទឹកបានដោះចេញពីជុំវិញកសិដ្ឋាន កំលាំងដោះទឹកបានទៅកាន់ប្រឡាយស្រោចស្រពឆ្លងកាត់តាមសំណង់បង្ហូរចេញទៅវាលស្រែ ។ ដូចជាការហូរចូលដោយប្រើប្រាស់ចន្លោះសេរីក្នុងការដោះទឹក ឬសមត្ថភាពដែលមានស្រាប់នៃប្រឡាយ ។

6) **ការត្រួតពិនិត្យផ្លូវ**

ប្រឡាយមេ និង ប្រឡាយរងជារបស់ផ្ទៃដីស្រោចស្រពលើសពី 1,100 ហិចតាត្រូវមានការត្រួតពិនិត្យផ្លូវដែលទទឹងខ្នងសរុប 5 ម. ។ ការត្រួតពិនិត្យផ្លូវត្រូវបានប្រើប្រាស់សំរាប់យានជំនិះ ។ ប្រឡាយសំរាប់ផ្ទៃដីស្រោចស្រពតិចជាង 1,000 ហិចតា ត្រូវមានទំហំតូចជាង ហើយការងារថែទាំមិនត្រូវការចាំបាច់សាងសង់ដោយម៉ាស៊ីន ។ ដូច្នេះទទឹងខ្នងសរុបការត្រួតពិនិត្យរបស់ផ្លូវសំរាប់ប្រឡាយរងតិចជាង 1,000 ហិចតា គឺ 2,0 ម. ដែលមួយណាក៏អាចធ្វើដំណើរបានដោយម៉ូតូ ។ ក្នុងនេះប្រឡាយដែលរត់តាមបណ្តោយផ្លូវដែលមានស្រាប់ ដែលបំពេញតំរូវចិត្តរបស់ទំហំទទឹងខ្នងអធិប្បាយខាងលើការត្រួតពិនិត្យផ្លូវមិនត្រូវបានស្នើរឡើង ។

7) **សំណង់ឆ្លងកាត់ទទឹង**

សំណង់លូកាត់ទទឹង និង សំណង់លូទឹកតាមផ្លូវ ត្រូវបានរៀបចំជាមួយលូបេតុង ។ មុខកាត់លូតូចបំផុតគឺ 0, 60 ម.។

8) **ឧបករណ៍វាស់វែង**

ឧបករណ៍ស្ទង់មើលកំរិតកំពស់ទឹក 2 ត្រូវបានភ្ជាប់ភាពងាយស្រួលផ្សេងៗ ពីប្រឡាយមេទៅកាន់ប្រឡាយរង ។ ឧបករណ៍ស្ទង់មើលត្រូវបានប្រគល់ឱ្យទាំងពីរផ្នែកខាងលើនៃប្រឡាយ (ប្រឡាយមេ) និង ផ្នែកខាងក្រោមនៃប្រឡាយ (ប្រឡាយរង) ។ ការស្រោចស្រពសារចុះសារឡើងត្រូវបានផ្តល់ឱ្យប្លុកប្រឡាយស្រោចស្រពប្រើជាប្រយោជន៍ បន្ទាប់មកការបែងចែកទឹកសំរាប់ប្លុក

ប្រឡាយស្រោចស្រពត្រូវបានត្រួតពិនិត្យដោយពេលវេលា ។ រាល់ការបើកទ្វារទឹកត្រូវបានត្រួតពិនិត្យ និង ប្រតិបត្តិតាមកំរិតកំពស់ទឹកក្នុងប្រឡាយស្រោចស្រព ។

(3) **ស្រះទឹក**

1) **ស្រះទឹក**

ជំរៅស្រះទឹកដែលបានជីកគួរតែ 3 ម. ដូច្នេះ ចំនួនទឹកក្រោមដីពិតប្រាកដដែលប្រើប្រាស់ជាប្រយោជន៍បាន ។ ជំរេលជើងទេរនៃស្រះ 1:2.0 ហើយស្រទាប់ខាងក្នុងនៃជើងទេរមិនត្រូវបានពិចារណា ។ ជុំវិញស្រះទឹកគួរតែសង់ឡើងនូវភ្លឺតូចៗដើម្បីជៀសវាងសំណឹកតាមជើងទេរ ។

2) **សំណង់ដែលជាប់ទាក់ទងផ្សេងៗ**

កាំជណ្តើរឈើ និង របងព័ទ្ធជុំវិញភ្លឺស្រះគួរតែមានរួមជាមួយផងដែរ ។

## 13.2.3 សំណង់ដោះទឹក

(1) **គោលនយោបាយធ្វើឱ្យល្អឡើងវិញ**

នៅក្នុងប្រទេសកម្ពុជាការដាំដុះស្រូវបានប្រើប្រាស់លក្ខខ័ណ្ឌទឹកជំនន់មានឈ្មោះថា " ការដាំដុះបណ្តាញទឹក " គឺនៅក្នុងតំបន់ជាច្រើន ។

ទោះបីយ៉ាងណាក៏ដោយ ការដោះទឹកគួរតែជាមូលដ្ឋានក្នុងការគ្រោងដែលមានសមត្ថភាពគ្រប់គ្រាន់ឆ្ពោះទៅកាន់ទីបញ្ចប់ហៅថាទន្លេ ឬ ស្ទឹង ។ ប្រសិនបើសមត្ថភាពដែលមានស្រាប់នៃទីបញ្ចប់ ទន្លេ ឬ ស្ទឹង មិនអាចគ្រប់គ្រាន់ សមត្ថភាពគួរតែបានពង្រីកឱ្យធំដោយការជីក ឬ ការសាងសង់ទំនប់ ។ ការពិចារណាដីលើសលប់បរិមាណនៃការងារសំរាប់ការងារសាងសង់ទំនប់ ការធ្វើឱ្យល្អឡើងវិញការដោះទឹកដែលបានពិចារណាសំរាប់តំបន់ដែលការដោះទឹកមានស្រាប់ ស្ទឹង ឬ ទន្លេ ជាមួយនឹងសមត្ថភាពទទួលបានគ្រប់គ្រាន់ ។

(2) **សមត្ថភាពគ្រោង**

សំរាប់ផែនការស្តារ និង ជួសជុលឡើងវិញប្រព័ន្ធស្រោចស្រពការដោះទឹកគឺត្រូវបានពិចារណាជាបឋម " ដោះទឹកពីការស្រោចស្រពទៅតំបន់ខាងក្រៅ " សំរាប់ការថែទាំនៃលក្ខខ័ណ្ឌដែលមានស្រាប់ ។ ប្លុកប្រឡាយស្រោចស្រពគួរតែមានទីវាលសំរាប់ដោះទឹកដែលមានសមត្ថភាពសរុបស្មើនឹង សមត្ថភាពរបស់ប្រឡាយស្រោចស្រព ។ ការដោះទឹកពីប្រឡាយស្រោចស្រពគួរតែបានភ្ជាប់ទៅនឹងសំណង់ដោះទឹកធំមួយ ឬ ប្រឡាយស្រោចស្រពសំរាប់តំបន់ក្រោមប្រឡាយដើម្បីយកទឹកដែលដោះចេញមកប្រើជាថ្មី ។

ក្នុងករណីនេះ សមត្ថភាពរបស់ប្រឡាយដែលមានស្រាប់ ហើយ ទន្លេមានសមត្ថភាពទទួលបានគ្រប់គ្រាន់ ការធ្វើឱ្យល្អឡើងវិញនូវសំណង់ដោះទឹកត្រូវបានពិចារណាជាមួយតំរូវការចំនួនទឹកដែលត្រូវដោះចេញសំរាប់រយៈពេលភ្លៀង 3 ថ្ងៃ ក្នុង 10 ឆ្នាំមានឡើងវិញម្តងដែលកើតឡើងការជន់លិចក្នុងរយៈពេល 3 ថ្ងៃ ចំនួនតំរូវការទឹកត្រូវថយចុះដោយការគណនា ក្នុងការរក្សាទឹកទុក (សមត្ថភាពផ្ទុកទឹក) ក្នុងវាលស្រែ ។ ក្នុងផ្នែករង 13.6.7 បានអធិប្បាយលំអិត " គ្រោងការបឋមនៃប្រព័ន្ធប្រឡាយ " ។

### 13.2.4 ការទទួលខុសត្រូវ

**(1) ការសាងសង់**

សេវាកម្មវិស្វកម្មសំរាប់ប្រព័ន្ធ និង ការសាងសង់នៃប្រព័ន្ធស្រោចស្រពដែលប្រកបឡើងដោយសំណង់បង្វែរទឹក អាងទឹក ប្រឡាយមេ ប្រឡាយរង និង ប្រឡាយស្រោចស្រពដែលបានដំណើរការដោយសេវាកម្មសាធារណៈ (MOWRAM) ។ ការសាងសង់ផ្លូវទឹកត្រូវបានដំណើរការដោយអ្នកទទួលផលដែលទទួលការណែនាំបច្ចេកទេសពី (MOWRAM) ។

**(2) ប្រតិបត្តិការ និង ការថែទាំ**

យោងតាមនយោបាយរបស់រាជរដ្ឋាភិបាល សំណង់ស្រោចស្រព និង សំណង់ដោះទឹកគួរបានប្រគល់ឱ្យសហគមន៍កសិករប្រើប្រាស់ទឹក ហើយសហគមន៍កសិករប្រើប្រាស់ទឹក (FWUC) គួរប្រតិបត្តិការ និង ការថែទាំ (O & M) ដោយភ្លាមៗបន្ទាប់ពីការបញ្ចប់នៃការសាងសង់ ។

ទោះបីជាយ៉ាងណាក៏ដោយ សំរាប់ប្រព័ន្ធខ្នាតធំល្មម វាជាការលំបាកសំរាប់អ្នកទទួលផលទទួលធ្វើប្រតិបត្តិការ និង ការថែទាំ (O & M) ដោយភ្លាមៗបន្ទាប់ពីការបញ្ចប់នៃការសាងសង់ ។

លើការបំពាក់បំប៉នការងារនៃសហគមន៍កសិករប្រើប្រាស់ទឹក (FWUC) សំរាប់រយៈពេលពិតប្រាកដ (ឧទាហរណ៍ 4 ឆ្នាំ) បន្ទាប់ពីការសាងសង់ត្រូវបានប្រតិបត្តិដោយ (MOWRAM) ។

## 13.3 ការចិតជិតនៃផែនការប្រព័ន្ធស្រោចស្រព

ប្រព័ន្ធស្រោចស្រព ជាទូទៅត្រូវបានរៀបចំដោយយោងតាមដំណើរការដូចខាងក្រោម :

### (1) ការវិភាគនៃជលសាស្ត្រ

ការវិភាគនៃជលសាស្ត្រ គួរបានធ្វើលើទឹកដែលរកបាន និង ទឹកជំនន់សំរាប់មូលដ្ឋានរៀបចំប៉ារ៉ាម៉ែត្រដើម្បីគ្រោងនៃប្រព័ន្ធបង្ហូរទឹក និង សំរាប់ផែនការនៃប្រព័ន្ធស្រោចស្រព ។ រាល់កន្លះខែ ឬ មួយខែនៃរំហូរ 80% ភាពដែលអាចទុកចិត្តបានដែលបានស្នើរនៃទីតាំងសំណង់បង្ហូរចូល គួរតែបានធ្វើការប៉ាន់ស្មានតាម បរិមាណទឹកដែលអាចរកបាន ហើយការគ្រោងទឹក ជំនន់នៃរយះទឹកជំនន់មានឡើងវិញចំពោះខ្លួនគួរបានប៉ាន់ស្មាន សំរាប់ការគ្រោងសំណង់បង្វែរ និង សំណង់ទ្វារទឹកនៃអាងទឹក និង សំណង់ដោះទឹក ។



រូបភាព. ផែនការប្រព័ន្ធស្រោចស្រព

### (2) ការប៉ាន់ស្មាននៃតំរូវការទឹកក្នុងការស្រោចស្រព

តំរូវការទឹក ការស្រោចស្រពគឺបានប៉ាន់ស្មានពីការប្រើប្រាស់ទឹកសំរាប់តំរូវការ ដែលស្នើរឡើងដោយដំណាំ ដោយធ្វើការប៉ាន់ស្មានលើមូលដ្ឋានសក្តានុពលភាពនៃរំហួត ។ លំអិតនៃដំណើរការប៉ាន់ស្មានតំរូវការទឹក ក្នុងការស្រោចស្រពបានអធិប្បាយក្នុងផ្នែក 13.4. ។

### (3) គុណភាពទឹក

គុណភាពទឹកគឺបានប្រព្រឹត្តទៅលើមូលដ្ឋានទឹកដែលរកបាន និង តំរូវការស្រោចស្រពផ្ទៃដីស្រោចស្រពគឺបានប៉ាន់ស្មានដោយបែងចែកបរិមាណទឹក ដែលរកបានដោយឯកតាតំរូវការទឹកក្នុងការស្រោចស្រពបានអធិប្បាយក្នុងផ្នែក 13.4. ។

### (4) ការសំរេចចិត្តពិតប្រាកដនៃផ្ទៃដីស្រោចស្រព

យោងតាមការប៉ាន់ស្មាន ផ្ទៃដីស្រោចស្រពក្នុងការសិក្សាគុណភាពទឹក ផ្ទៃដីស្រោចស្រពត្រូវបានពណ៌នាលើផែនទី ។ វាគួរបានសំគាល់ថាផ្ទៃដីស្រោចស្រព " ផ្ទៃដីសុទ្ធសាធ " ហៅថាផ្ទៃដីដាំដុះ ។ ខណៈដែល " ផ្ទៃដីសរុប" ដែលរួមជាមួយដីប្រឡាយ ដីភ្លឺស្រែ ដីផ្លូវ ។ល។

(5) **ប្រព័ន្ធផែនការ**

យោងតាមផ្ទៃដីស្រោចស្រព បានពណ៌នាលើផែនទី បានសំរេចចិត្តពិតប្រាកដប្លុកស្រោចស្រពសំរាប់ប្រព័ន្ធប្រឡាយនីមួយៗ ។

## 13.4 គំរូការទឹកស្រោចស្រព

### 13.4.1 ការអនុវត្តន៍ប្រព័ន្ធឥវាល

វិធីសាស្ត្រស្រោចស្រពទីវាលគឺរតធំ រួមជាមួយប្រសិទ្ធិភាពស្រោចស្រព។ នៅក្នុងផ្នែកបន្ទាប់នេះ វិធីសាស្ត្រការស្រោចស្រពទីវាលសំរាប់ស្រូវ និង ដំណាំរួមផ្សំ បានពិភាក្សាជាអាទិភាពក្នុងការប៉ាន់ស្មាននៃតំរូវការទឹកស្រោចស្រព ។

(1) **វិធីសាស្ត្រស្រោចស្រពសំរាប់ការដាំស្រូវ**

1) ការស្រោចស្រពដោយស្រះទឹក

ការស្រោចស្រពដោយស្រះទឹក គឺជាបែបផែនវិធីសាស្ត្រស្រោចស្រពមួយសំរាប់ការដាំស្រូវ។ វាងស្រែគឺព័ទ្ធជុំវិញដោយភ្លឺដែលមានកំពស់ប្រហែល 20 សម. ។ ទឹកស្រោចស្រពគឺបានរក្សាទុកក្នុងវាលស្រែដែលបានស្ទូងស្រូវ ។ គុណសម្បត្តិ និង គុណវិបត្តិនៃវិធីសាស្ត្រស្រោចស្រពដោយស្រះទឹកបានបង្ហាញតាម :

<u>គុណសម្បត្តិ :</u>

- ត្រួតពិនិត្យស្មៅងាយស្រួល
- ងាយស្រួលគ្រប់គ្រងទឹក ( មិនចាំបាច់ធ្វើការកែសំរួលឱ្យបានញឹកញាប់)
- ការប្រើជីបានផលយូរ
- ការកករងឃឹតៗនៃសារធាតុរុក្ខជាតិតូចៗដែលមានជាតិពុល ។ល។




រូបភាព. ការស្រោចស្រពដោយស្រះទឹក

## 2) ការស្រោចស្រពដោយសន្សំសំចៃទឹក

ថ្វីត្បិតគុណសម្បត្តិការស្រោចស្រពដោយស្រះទឹកបានអធិប្បាយខាងលើ ស្រូវមិនត្រូវការជីវសាស្ត្រស្រះទឹកដោយខ្លួនវា វិធីសាស្ត្រស្រោចស្រពដោយសន្សំសំចៃទឹកគឺ ដំណើរការទឹកចាំបាច់ដែលបានមក អំឡុងពេលយ៉ាងសំខាន់នៃរយៈពេលកំពុងធំធាត់ដល់រយៈពេលមានផ្លែផ្កាកើតឡើង ហើយផ្តល់ទឹកតិចបំផុតដើម្បីរក្សាឱ្យសើមក្នុងអំឡុងរយៈពេលធំធាត់ផ្សេង១ទៀត។ ដោយវិធីសាស្ត្រផ្លាស់ប្តូរវាលស្រែត្រូវបានថែទាំ ឬ ត្រូវបានធ្វើឱ្យល្អឡើងវិញ ។ ទោះបីយ៉ាងណា ការរាយការណ៍អំពីការគ្រប់គ្រងទឹក ជាតំរូវការចាំបាច់សំរាប់វិធីសាស្ត្រនេះ ។

ជាឧទាហរណ៍ កំពស់ទឹកត្រូវការបានថយចុះ 25 % ដោយការអនុវត្តន៏វិធីសាស្ត្រស្រោចស្រពដោយសន្សំសំចៃទឹកសំរាប់ផែនការស្រោចស្រពអាងទឹកខាងលើស្ទឹងស្លាគូ (USP) ។




រូបភាព. ការស្រោចស្រពដោយសន្សំសំចៃទឹក

ការប្រតិបត្តិដោយវិធីសាស្ត្រស្រោចស្រពដោយសន្សំសំចៃទឹក គឺបានរៀបរាប់ក្នុងផ្នែកបន្ទាប់ 16.2 " ការប្រតិបត្តិនៃសំណង់ផ្សេង១ " ។

## 3) ការស្រោចស្រពពីស្រែមួយទៅស្រែមួយ ( ការស្រោចស្រពស្ទឹត)

ប្រព័ន្ធស្រោចស្រពដែលមានស្រាប់ជាច្រើន មានការខ្វះខាតបណ្តាញប្រឡាយស្រោចស្រពទីវាល ហើយទឹកបានចែកពីស្រែមួយទៅស្រែមួយទៀត ។ ក្នុងករណីនេះ ទឹកស្រោចស្រពទៅកាន់ស្រែខាងចុងគឺមិនបានធានា ពីព្រោះទឹកមិនបានទៅដល់ លើកលែងតែស្រែក្នុងតំបន់ខាងលើបានទទួលការស្រោចស្រពគ្រប់គ្រាន់ ។ ការអនុវត្តន៏ការស្រោចស្រពទឹកពីស្រែមួយទៅស្រែមួយគឺ មូលហេតុដ៏ធំមួយនៃពេលវេលាដាំដុះ និង មានភាពលំបាកក្នុងការគ្រប់គ្រងទឹក ។ ប្រឡាយស្រោចស្រព និង ផ្លូវទឹកគួរបានសាងសង់ឡើងក្នុងភាពសមរម្យ ដែលរយៈចំងាយខិតជិតពីស្រែមួយទៅស្រែមួយទៀត ដើម្បីបែងចែកឱ្យបានទាំងអស់ ។

### (2) វិធីសាស្ត្រស្រោចស្រពសំរាប់ការដាំដំណាំរួមផ្សំ

#### 1) ការស្រោចស្រពដោយភ្លូរជាចង្អូរ

ការស្រោចស្រពសំរាប់ដំណាំរួមផ្សំ គឺជាទូទៅប្រព្រឹត្តទៅបានតាមការស្រោចស្រពដោយកាយ ឬ ភ្លូរជាចង្អូរ ។ ដំណាំបន្ទាប់បន្សំ និង បន្លែ បានដាំក្នុងវាលស្រែដែលពេញដោយដំណាំមានទំរង់ជាជួរនៅទីវាល ដូច្នេះការធ្វើដីឱ្យសើមក្នុងភាពសមរម្យតំបន់ផ្លូវទឹកដែលបានបង្ហូរ ។ ការស្រោចស្រពដោយភ្លូរជាចង្អូរ គឺបានប្រព្រឹត្តទៅដោយបែងចែកទឹកឆ្លោះទៅស្នាមភ្លោះចន្លោះជាជួរៗ ។ ប្រសិទ្ធិភាពការស្រោចស្រពដោយភ្លូរជាចង្អូរមិនបានខ្ពស់ទេពីព្រោះទឹកជ្រាបចូលផងដែរទៅក្នុងដីផ្នែកក្រៅរងដំណាំ ។




រូបភាព. ការស្រោចស្រពដោយភ្លូរជាចង្អូរ

#### 2) ការស្រោចស្រពដោយកំលាំង (Mannual Irrigation)

ការស្រោចស្រពដោយកំលាំងគឺបានប្រព្រឹត្តទៅដោយកំលាំងមនុស្សជាមួយប៉ោតទឹក ។ ទឹកពេលខ្លះបានរក្សានៅទីរក្សាទឹក ហើយបានស្រោចស្រពពីដំណាំមួយគុម្ពទៅដំណាំមួយគុម្ព ។ វិធីសាស្ត្រការស្រោចស្រពដោយកំលាំងមិនអាចអនុវត្តន៍សំរាប់ផ្ទៃដីស្រោចស្រពធំបានទេ ប៉ុន្តែប្រសិទ្ធិភាពការស្រោចស្រពគឺមានកំរិតខ្ពស់ ។

## 13.4.2 តំរូវការទឹក ស្រោចស្រពសុទ្ធ

ក្នុងផ្នែកនេះ ពន្យល់ពីវិធីសាស្ត្រសំរាប់ការប៉ាន់ស្មានតំរូវការទឹកស្រោចស្រពក្នុងការចុះសម្រុងគ្នាជាមួយការស្រោចស្រព និង ការដោះទឹកចេញឯកសារលេខ 24 ។ សំរាប់ការស្រោចស្រពដោយសន្ទំសំចៃទឹកការស្រោចស្រព និង ដោះទឹកចេញរបស់អង្គការ FAO ឯកសារលេខ 33 អាចបញ្ជាក់បាន ។

### (1) ស្រូវ

រូបភាព 13.5 បង្ហាញពីដំណើរការគណនានៃតំរូវការទឹកស្រោចស្រពសំរាប់វាលស្រែ ។

1) ទិន្នន័យ និង តំរូវការពតិមាន

តំរូវការទិន្នន័យ និង ពតិមាន មានទិន្នន័យទឹកភ្លៀង ទិន្នន័យអាកាសធាតុ តំរូវជាំដុះនឹងហូរជ្រាបបាត់បង់ក្នុងវាលស្រែ ។ ទិន្នន័យភ្លៀងប្រចាំថ្ងៃ គួរតែបានប្រមូល ។ ទិន្នន័យអាកាសធាតុគួរតែប្រកបឡើងដោយសីតុណ្ហភាព សំណើម ពន្លឺព្រះអាទិត្យ និង ល្បឿនខ្យល់ ។

2) តំរូវការទឹកស្រោចស្រពក្នុងថ្នាលសំណាលសុទ្ធ

$$NIWR_n = LP + CU + P - ER$$

ដែល, $NIWR_n$ : តំរូវការទឹកស្រោចស្រពសំណាប (មម)

LP: តំរូវការទឹកសំរាប់ការរៀបចំដី (មម).

តំរូវការទឹកសំរាប់រៀបចំដី ជាធម្មតាធ្វើជាផ្លូវពី 100 មម. ទៅ 200 មម. អាស្រ័យលើគុណសម្បត្តិដី និង ដីមានជាតិទឹក ។ ក្នុងរដូវភ្លៀងដំបូង ដីដែលមានជាតិទឹកគឺកំរិតទាប ដូច្នេះហើយតំរូវការទឹកសំរាប់ការរៀបចំដីគឺច្រើន ។ នៅពេលរដូវភ្លៀងធ្លាក់ជោគជាំខ្លាំង គឺខែកញ្ញា ដីទំនេរភាគច្រើនពេញដោយទឹក ដូច្នេះហើយតំរូវការទឹកសំរាប់រៀបចំដីគឺទាបណាស់ ។ ផ្ទៃដីដែលធ្លាប់លិចទឹក ដូចជាផ្ទៃដីនៅផ្នែកខាងក្រោមអាងទឹកត្នោតទេរ មិនត្រូវការទឹកសំរាប់រៀបចំដីទេ ពីព្រោះទឹកដែលសល់នៅអាចប្រើប្រាស់បានក្នុងដីទំនាប ។

តំរូវការទឹកសំរាប់ការរៀបចំដី

រដូវភ្លៀងដំបូង : 150 មម ~ 200 មម

ពាក់កណ្តាលរដូវភ្លៀង : 120 មម ~ 150 មម

រដូវភ្លៀងជោគជាំ : 50 មម ~ 100 មម

តំបន់ដែលធ្លាប់លិចទឹក : មិនត្រូវការ

CU: ទឹកប្រើប្រាស់សំរាប់ស្រោចស្រព (មម), CU = kc ETo

ដែល kc: មេគុណរបស់ដំណាំ

មេគុណរបស់ដំណាំ kc ជាធម្មតាគឺ 1.0 ក្នុងថ្នាលសំណាប

ETo: សក្តានុពលនៃរំហួត (មម) បានប៉ាន់ស្មានដោយវិធីសាស្ត្រកែខែរបស់ PENMAN ដែលបានពន្យល់ក្នុងផ្នែក (3) ។

P: ការបាត់បង់ដោយជំរាប (មម) ។

ER: បរិមាណទឹកភ្លៀងក្នុងករណីនេះ ការគណនាតំរូវការទឹកនៃសំណាប បរិមាណទឹកភ្លៀងជាញឹកញាប់មិនបានយកមកប្រើប្រាស់ ពីព្រោះតំរូវការទឹករបស់សំណាបតិច ។

3) តំរូវការទឹកស្រោចស្រពសុទ្ធ ក្នុងទីវាលធំ

$$NIWR_m = LP + (CU + P + S - ER)$$

ដែល $NIWR_m$ : តំរូវការទឹកស្រោចស្រពសុទ្ធក្នុងទីវាលធំ (មម)

LP: តំរូវការទឹកសំរាប់ការរៀបចំដី (មម)

ការរៀបចំដីសំរាប់ទីវាលធំ គឺ សំខាន់ប្រហាក់ប្រហែលទៅនឹងថ្នាលសំណាបដែរ ។

CU: ទឹកប្រើប្រាស់សំរាប់ស្រោច (មម), CU = kc ETo

ដែល kc: មេគុណដំណាំសំរាប់ដំណាក់កាលស្រូវធំធាត់ក្នុងរដូវភ្លៀងបានសន្មត់តាមការចុះសម្រុង ជាមួយនឹងការស្រោចស្រព និង ដោះទឹកចេញរបស់អង្គការ FAO ឯកសារលេខ 24 ។

តារាង Kc សំរាប់ស្រូវកណ្តាលរាល់កន្លះខែ

| ទី 1 | ទី 2 | ទី 3 | ទី 4 | ទី 5 | ទី 6 | ទី 7 |
|---|---|---|---|---|---|---|
| 1.10 | 1.10 | 1.10 | 1.05 | 1.05 | 1.05 | 0.95 |

តារាង Kc សំរាប់ស្រូវស្រាលរាល់កន្លះខែ

| ទី 1 | ទី 2 | ទី 3 | ទី 4 | ទី 5 |
|---|---|---|---|---|
| 1.10 | 1.10 | 1.05 | 1.05 | 0.95 |

ETo: សក្តានុពលរំហួត (មម) បានប៉ាន់ស្មានដោយវិធីសាស្ត្រកែខៃរបស់ PENMAN សូមមើលផ្នែក (3)

P: ជំរាប (មម)

ដីទំនាបជាច្រើនក្នុងខេត្តតាកែវស្ថិតនៅក្នុងក្រុមដី " ព្រៃខ្មែរ " ឬ " បន្ទះឡាង " ។ អាស្រ័យតាមការសាកល្បងដំណើរការដីទំនាបតាមបណ្តោយស្ទឹងស្លាគូ ការបាត់បង់ដោយជំរាបក្នុងក្រុមដីនេះ គឺបានប៉ាន់ស្មានប្រហាក់ប្រហែល 3 មម/1 ថ្ងៃ ។

ក្នុងការប៉ាន់ស្មាននៃតំរូវការទឹកស្រោចស្រព ការបាត់បង់ដោយជំរាបគួរបានគិតអំឡុងពេលតែមួយ រយៈពេលចាប់ផ្តើម 30 ថ្ងៃនៃរយៈពេលចេញពន្លកហូតដល់បញ្ចប់ពេលចេញផ្លែផ្កា ។ ការស្រោចស្រពដោយសន្សំសំចៃទឹកអាចធ្វើការសន្សំសំចៃទឹកពី 20 % ទៅ 25 % នៃតំរូវការទឹកស្រោចស្រពសុទ្ធសរុបធ្វើឡើងក្នុងតំបន់ដីទំនាបដែលការបាត់បង់ដោយជំរាបគឺ 2 មម ទៅ 3 មម/ 1 ថ្ងៃ ។ ការស្រោចស្រពបន្ថែមសំរាប់ការដុះពន្លក ល្មមសមគួរលិចទៅក្នុងទឹកគឺបានត្រូវការពេលផ្នែកខាងក្រៅនៃវាលស្រែស្ងួត ។ ចំនួនដែលបានស្រោចស្រពនេះគឺ 30 មម ។

ER: បរិមាណទឹកភ្លៀង(មម)

បរិមាណទឹកភ្លៀងគឺបានគណនាលើលក្ខខ័ណ្ឌដូចខាងក្រោម :

ពេលបរិមាណភ្លៀងប្រចាំថ្ងៃទាបជាង 5 មម. បរិមាណទឹកភ្លៀង = 0.0.

ពេលបរិមាណទឹកភ្លៀងប្រចាំថ្ងៃពីរយៈ 5 មម. ទៅ 80 មម. បរិមាណទឹកភ្លៀងគឺ 80 % នៃបរិមាណទឹកភ្លៀងប្រចាំថ្ងៃ ។

ពេលបរិមាណទឹកភ្លៀងប្រចាំថ្ងៃច្រើនជាង 80% បរិមាណទឹកភ្លៀងគឺ 64 មម.

ប្រសិនបរិមាណទឹកភ្លៀងប្រចាំថ្ងៃមិនអាចរកបាន បរិមាណទឹកភ្លៀងប្រចាំខែនឹងបង្រួមមក 75 % នៃបរិមាណទឹកភ្លៀងប្រចាំខែ ។

5) **តំរូវការទឹកស្រោចស្រពសុទ្ធសរុប**

$$NIWR_{paddy} = NIWR_n \times Af + NIWR_m$$

ដែល

$NIWR_{paddy}$: តំរូវការទឹកស្រោចស្រពសុទ្ធរបស់ស្រូវ

Af: ផ្ទៃដីសំរាប់ផលិត ។ ផ្ទៃដីសំណាបប្រហែល 5% នៃផ្ទៃដីស្រែធំ

ដូច្នេះ Af = 0.05

(2) **ដំណាំរួមផ្សំ ( ដំណាំចំការ )**

រូបភាព 13.6 បង្ហាញពីដំណើរការ ការគណនាតំរូវការទឹកស្រោចស្រពសំរាប់ដំណាំចំការ ។

$$NIWR_{crop} = LP + CU - ER$$

ដែល $NIWR_{crop}$: តំរូវការទឹកស្រោចស្រពសុទ្ធសំរាប់ដំណាំចំការ (មម)

LP: តំរូវការទឹកសំរាប់ការរៀបចំដី (មម)

ក្នុងករណីដែលស្រទាប់ដីហាប់ស្ងួត ហើយរឹងលំបាកក្នុងការផ្តល់ទឹកសំរាប់ការរៀបចំដី។ ពេលដំណាំចំការបានដាំក្នុងចុងរដូវភ្លៀង ខែ វិច្ឆិកា និង ធ្នូ ឬ ក្នុងអំឡុងរដូវភ្លៀង វាសង្ឃឹមថា បរិមាណដីស្រទាប់លើចំនួនទឹកល្មមសមគួរនិងធំធាត់អាចងាយស្រួលដល់ការអនុវត្តន៍ក្នុងរដូវភ្លៀង ទោះបីគ្មានទឹក ក៏មិនមែនជាសេចក្តីត្រូវការក្នុងការរៀបចំដីនោះទេ ។

CU: ទឹកប្រើប្រាស់សំរាប់ស្រោចស្រព (មម), CU = kc ETo

ដែល kc: មេគុណនៃដំណាំ

រយៈពេលធំធាត់ និង មេគុណដំណាំខុសគ្នារវាងប្រភេទផ្សេងៗ នៃការដាំដំណាំចំការពិតប្រាកដ ។ ក្នុងនេះ ផែនការស្រោចស្រពក្នុងគ្រោងការណ៍ចំបង និង ដំណាក់កាលការ

សិក្សា រយៈពេលការធំធាត់មធ្យម និង មេគុណដំណាំមធ្យមជាធម្មតាត្រូវបានទទួលយក មេគុណដំណាំតាមតារាងគឺតួយ៉ាងដូចជាមេគុណដំណាំមធ្យមនៃដំណាំចំការ ។

**តារាង Kc សំរាប់រាល់កន្លះខែ**

| ទី 1 | ទី 2 | ទី 3 | ទី 4 | ទី 5 | ទី 6 |
|---|---|---|---|---|---|
| 0.50 | 0.55 | 0.70 | 0.80 | 090 | 0.60 |

ETo: សក្តានុពលនៃរំហួត (មម.) បានប៉ាន់ស្មានដោយវិធីសាស្ត្រកែខៃរបស់ PENMAN សូមមើលផ្នែក (3)

ER: បរិមាណទឹកភ្លៀង (មម)

បរិមាណទឹកភ្លៀងសំរាប់ដំណាំចំការអាចប៉ាន់ស្មានបានដោយវិធីសាស្ត្រផ្សេងៗគ្នា ។ ទី 1 គឺការរំហួត / បរិមាណទឹកភ្លៀងនៃវិធីសាស្ត្រ តារាង 34 ក្នុងឯកសារលេខ 24 ការស្រោចស្រព និង ដោះទឹកចេញរបស់អង្គការ FAO ដូចបានបង្ហាញស្រាប់ ។

**តារាងមធ្យមភាគបរិមាណទឹកភ្លៀងប្រចាំខែដែលបានរៀបរាប់ទៅនឹងមធ្យមភាគប្រចាំខែនៃ ET ដំណាំហើយមានន័យថាបរិមាណទឹកភ្លៀងប្រចាំខែ (USDA (SCS), 1969)**

| | Monthly mean rainfall | 12.5 | 25.0 | 37.5 | 50.0 | 62.5 | 75.0 | 87.5 | **100** | 112.5 | 125.0 | 137.5 | 150.0 | 162.5 | 175.0 | 187.5 | 200.0 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| Mean monthly evapo-transpiration (m | 25 | 8 | 16 | 24 | | | | | | | | | | | | | |
| | 50 | 8 | 17 | 25 | 32 | 39 | 46 | | Average monthly effective rainfall | | | | | | | | |
| | 75 | 9 | 18 | 27 | 34 | 41 | 48 | 56 | 62 | 69 | | | | | | | |
| | 100 | 9 | 19 | 28 | 35 | 43 | 52 | 59 | 66 | 73 | 80 | 87 | 94 | 100 | | | |
| | 125 | 10 | 20 | 30 | 37 | 46 | 54 | 62 | 70 | 76 | 85 | 92 | 98 | 107 | 116 | 120 | |
| | **150** | 10 | 21 | 31 | 39 | 49 | 57 | 66 | **74** | 81 | 89 | 97 | 104 | 112 | 119 | 127 | 133 |
| | 175 | 11 | 23 | 32 | 42 | 52 | 61 | 69 | 78 | 86 | 95 | 103 | 111 | 118 | 126 | 134 | 141 |
| | 200 | 11 | 24 | 33 | 44 | 54 | 64 | 73 | 82 | 91 | 100 | 109 | 117 | 125 | 134 | 142 | 150 |
| | 225 | 12 | 25 | 35 | 47 | 57 | 68 | 78 | 87 | 96 | 106 | 115 | 124 | 132 | 141 | 150 | 159 |
| | 250 | 13 | 25 | 38 | 50 | 61 | 72 | 84 | 92 | 102 | 112 | 121 | 132 | 140 | 150 | 158 | 167 |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| 20 | 25 | 37.5 | 50 | 62.5 | 75 | 100 | 125 | 150 | **175** | 200 | <-Effective storage in soil (mm) |
| 0.73 | 0.77 | 0.86 | 0.93 | 0.97 | 1.00 | 1.02 | 1.04 | 1.06 | 1.07 | 1.08 | <-Storage factor |

**CALCULATION OF EFFECTIVE RAINFALL FOR UPLAND CROP**

| | | | |
|---|---|---|---|
| Mean monthly rainfall (mm) | 100.0 | mm | <- Data Input ! (12.5 - 200.0) |
| Mean potential evapotranspiration (mm) | 150.0 | mm | <- Data Input ! (25.0 - 250.0) |
| Effective storage of soil layer (mm) | 175.0 | mm | <- Data Input ! (20.0 - 200.0) |
| Effective rainfall for 75 mm (mm) | 74.0 | mm | |
| Storage factor | 1.07 | | |
| Effective rainfall (mm) | **79.2** | mm | <- This is the result ! |

ពេលបរិមាណទឹកភ្លៀងមានការរអាក់រអួលក្នុងការប៉ាន់ស្មាន ឬ ប្រភេទដំណាំដែលបានដាំមិនបានរៀបចំទៀងទាត់ បរិមាណទឹកភ្លៀងប្រចាំខែអាចបង្រួមបានមកត្រឹម 75% ភ្លៀងប្រចាំខែ ។

(3) **សក្តានុពលនៃរំហួត (ETo)**

សមីការនៃវិធីសាស្ត្រកែខៃរបស់ PENMAN គឺ

$$ETo = c\,[\underbrace{W\,Rn}_{\text{រយៈពេលការភាយ}} + \underbrace{(1-W)\,f(u)\,(ea-ed)}_{\text{រយៈពេលអេរ៉ូឌីណាមិច}}]$$

ដែល W: សីតុណ្ហភាពដែលជាប់ទាក់ទងភាគរយនៃបន្ទុក

Rn: ការសាយភាយសុទ្ធដែលស្មើនឹងរំហួតគិតជា មម/ថ្ងៃ

f(u): ការធ្វើអំពើនៃខ្យល់ដែលជាប់ទាក់ទង

(ea-ed): ភាពខុសគ្នារវាងការភាយចំហាយទឹក មានន័យថាសីតុណ្ហភាពនៃខ្យល់ហើយ មានន័យថារំហួតពិតប្រាកដរបស់ខ្យល់ ឬ ការបញ្ឈប់ទាំង 2 ។

c: ការធ្វើឱ្យស្មើគ្នាសំរាប់បន្ទុកជាក់លាក់រវាងពេលថ្ងៃ និង ពេលយប់ នៃលក្ខខ័ណ្ឌអាកាសធាតុ ។

គំរូយ៉ាងការគណនាសំរាប់ប៉ាន់ស្មាន ETo ដោយវិធីសាស្ត្រកែខៃរបស់ PENMAN ដូចបានបង្ហាញតាមតារាងខាងក្រោម ។ តារាងលំអិតនឹងបានប្រឹក្សាយោបល់ទៅលើការស្រោចស្រព និង ដោះទឹកចេញរបស់អង្គការ FAO ឯកសារលេខ 24 ។

## តារាង : ការគណនានៃរំហួតដោយវិធីសាស្ត្រកែខៃរបស់ PENMAN

Pochentong Station (11°North, 10 m in Altitude)

| | | Jan. | Feb. | Mar. | Apr. | May | Jun. | Jul. | Aug. | Sept. | Oct. | Nov. | Dec. | Remarks |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| A | Tmean (℃) | 26.3 | 27.6 | 29.3 | 30.1 | 29.9 | 28.9 | 28.2 | 28.2 | 27.9 | 27.2 | 26.5 | 25.9 | Input |
| B | RHmean (%) | 72.9 | 70.5 | 70.6 | 71.4 | 76.4 | 78.8 | 82.3 | 82.9 | 85.5 | 86.0 | 79.6 | 75.2 | Input |
| C | ea (mbar) | 34.2 | 36.9 | 40.7 | 42.6 | 42.1 | 39.9 | 38.4 | 38.3 | 37.5 | 36.2 | 34.7 | 33.4 | from Table 5 |
| D | ed (mbar) | 24.9 | 26.0 | 28.7 | 30.4 | 32.2 | 31.4 | 31.6 | 31.8 | 32.1 | 31.1 | 27.6 | 25.1 | D=CxB/100 |
| E | (ea-ed) (mbar) | 9.3 | 10.9 | 12.0 | 12.2 | 9.9 | 8.5 | 6.8 | 6.6 | 5.4 | 5.1 | 7.1 | 8.3 | E=D-C |
| F | Wind, Vw (m/s) | 3.1 | 3.9 | 4.1 | 3.8 | 4.1 | 4.6 | 3.9 | 5.0 | 4.3 | 2.7 | 3.6 | 3.7 | Input, 12 m above |
| | Wind, Vw (m/s) | 2.1 | 2.7 | 2.9 | 2.6 | 2.8 | 3.2 | 2.7 | 3.5 | 3.0 | 1.9 | 2.5 | 2.6 | at 2m above GL |
| G | U (km/day) | 184.6 | 235.4 | 249.1 | 227.6 | 246.2 | 279.4 | 234.8 | 301.5 | 258.7 | 164.7 | 216.9 | 220.9 | |
| H | f(u) | 0.77 | 0.91 | 0.94 | 0.88 | 0.93 | 1.02 | 0.90 | 1.08 | 0.97 | 0.71 | 0.86 | 0.87 | |
| I | (1-W) of wind & numidity | 0.25 | 0.24 | 0.23 | 0.22 | 0.23 | 0.23 | 0.23 | 0.23 | 0.24 | 0.24 | 0.25 | 0.26 | Table 8 |
| J | Sunshine, n (hr) | 8.7 | 8.6 | 8.6 | 8.3 | 7.3 | 6.1 | 5.8 | 5.9 | 5.6 | 5.8 | 7.4 | 8.4 | Input |
| K | W of radiation | 0.75 | 0.76 | 0.78 | 0.78 | 0.78 | 0.77 | 0.77 | 0.77 | 0.76 | 0.76 | 0.75 | 0.74 | Table 9 |
| L | Ra (mm/day) | 13.00 | 14.00 | 15.20 | 15.70 | 15.60 | 15.40 | 15.40 | 15.50 | 15.30 | 14.60 | 13.50 | 12.70 | Table 10 |
| M | N (hr) | 11.50 | 11.80 | 12.00 | 12.30 | 12.60 | 12.70 | 12.60 | 12.40 | 12.10 | 11.80 | 11.60 | 11.50 | Table 11 |
| N | n/N | 0.76 | 0.73 | 0.71 | 0.68 | 0.58 | 0.48 | 0.46 | 0.48 | 0.47 | 0.49 | 0.64 | 0.73 | N=J/M |
| O | Rs (mm/day) | 8.2 | 8.6 | 9.2 | 9.2 | 8.4 | 7.5 | 7.4 | 7.6 | 7.4 | 7.2 | 7.7 | 7.8 | O=(0.25+0.5xN)xL |
| P | Rns (mm/day) | 6.1 | 6.5 | 6.9 | 6.9 | 6.3 | 5.7 | 5.5 | 5.7 | 5.5 | 5.4 | 5.8 | 5.9 | P=(1-α)xO, α = 0.25 |
| Q | f(Tmean) | 15.9 | 16.2 | 16.5 | 16.7 | 16.6 | 16.4 | 16.3 | 16.3 | 16.2 | 16.1 | 16.0 | 15.8 | Table 13 |
| R | f(ed) | 0.12 | 0.12 | 0.10 | 0.10 | 0.09 | 0.09 | 0.09 | 0.09 | 0.09 | 0.09 | 0.11 | 0.12 | $R=0.34-0.044xD^{0.5}$ |
| S | f(n/N) | 0.78 | 0.76 | 0.74 | 0.71 | 0.62 | 0.53 | 0.51 | 0.53 | 0.52 | 0.54 | 0.67 | 0.76 | S=0.1+0.9xN |
| T | Rnl (mm/day) | 1.5 | 1.4 | 1.3 | 1.1 | 0.9 | 0.8 | 0.8 | 0.8 | 0.8 | 0.8 | 1.2 | 1.4 | T=QxRxS |
| U | Rn (mm/day) | 4.6 | 5.0 | 5.6 | 5.8 | 5.4 | 4.8 | 4.8 | 4.9 | 4.8 | 4.6 | 4.6 | 4.4 | U=P-T |
| V | c | 0.99 | 1.00 | 1.01 | 1.00 | 0.98 | 0.97 | 0.97 | 0.95 | 0.95 | 0.98 | 0.98 | 0.98 | Table 16 |
| W | ETo (mm/day) | 5.2 | 6.2 | 7.0 | 6.9 | 6.2 | 5.6 | 4.9 | 5.1 | 4.7 | 4.3 | 4.9 | 5.0 | W=Vx(KxU+IxHxE) |

តារាងលើទំព័រទាំងអស់បានទទួលពីការអធិប្បាយឯកសារខាងលើ

# តារាង : ប៉ារ៉ាម៉ែត្រ បានប្រើប្រាស់ក្នុងឯកសារស្រោចស្រព និង ដោះទឹក FAO លេខ 24

Table 5 (page 21)

| Tmean | ea | Tmean | ea |
|---|---|---|---|
| 20 | 23.4 | 21 | 24.9 |
| 21 | 24.9 | 22 | 26.4 |
| 22 | 26.4 | 23 | 28.1 |
| 23 | 28.1 | 24 | 29.8 |
| 24 | 29.8 | 25 | 31.7 |
| 25 | 31.7 | 26 | 33.6 |
| 26 | 33.6 | 27 | 35.7 |
| 27 | 35.7 | 28 | 37.8 |
| 28 | 37.8 | 29 | 40.1 |
| 29 | 40.1 | 30 | 42.4 |
| 30 | 42.4 | 31 | 44.9 |
| 31 | 44.9 | 32 | 47.6 |
| 32 | 47.6 | 33 | 50.3 |
| 33 | 50.3 | 34 | 53.2 |
| 34 | 53.2 | 35 | 56.2 |
| 35 | 56.2 | 36 | 59.4 |

Table 8 (page 24)

| Tmean | (1-W) |
|---|---|
| 20 | 0.32 |
| 21 | 0.315 |
| 22 | 0.29 |
| 23 | 0.28 |
| 24 | 0.27 |
| 25 | 0.26 |
| 26 | 0.25 |
| 27 | 0.24 |
| 28 | 0.23 |
| 29 | 0.23 |
| 30 | 0.22 |
| 31 | 0.21 |
| 32 | 0.20 |
| 33 | 0.20 |
| 34 | 0.19 |
| 35 | 0.18 |

at altitude 0 m

Table 9 (page 24)

| Tmean | W |
|---|---|
| 20 | 0.69 |
| 21 | 0.70 |
| 22 | 0.71 |
| 23 | 0.72 |
| 24 | 0.73 |
| 25 | 0.74 |
| 26 | 0.75 |
| 27 | 0.76 |
| 28 | 0.77 |
| 29 | 0.78 |
| 30 | 0.78 |
| 31 | 0.79 |
| 32 | 0.80 |
| 33 | 0.81 |
| 34 | 0.82 |
| 35 | 0.83 |

at altitude 0 m

Table 13 (page 27)

| Tmean | f(Tmean) | Tmean | f(Tmean) |
|---|---|---|---|
| 20.0 | 14.6 | 28.0 | 16.3 |
| 20.5 | 14.7 | 28.5 | 16.4 |
| 21.0 | 14.8 | 29.0 | 16.5 |
| 21.5 | 14.9 | 29.5 | 16.6 |
| 22.0 | 15.0 | 30.0 | 16.7 |
| 22.5 | 15.1 | 30.4 | 16.8 |
| 23.0 | 15.2 | 30.8 | 16.9 |
| 23.5 | 15.3 | 31.2 | 17.0 |
| 24.0 | 15.4 | 31.6 | 17.1 |
| 24.4 | 15.5 | 32.0 | 17.2 |
| 24.8 | 15.6 | 32.4 | 17.3 |
| 25.2 | 15.7 | 32.8 | 17.4 |
| 25.6 | 15.8 | 33.2 | 17.5 |
| 26.0 | 15.9 | 33.6 | 17.6 |
| 26.5 | 16.0 | 34.0 | 17.7 |
| 27.0 | 16.1 | 34.5 | 17.8 |
| 27.5 | 16.2 | 35.0 | 17.9 |

Table 10 (page 25)

Northern Hemisphere

| North Lat | Jan. | Feb. | Mar. | Apr. | May | Jun. | Jul. | Aug. | Sept. | Oct. | Nov. | Dec. |
|---|---|---|---|---|---|---|---|---|---|---|---|---|
| 12 | 12.8 | 13.9 | 15.1 | 15.7 | 15.7 | 15.5 | 15.5 | 15.6 | 15.2 | 14.4 | 13.3 | 12.5 |
| 10 | 13.2 | 14.2 | 15.3 | 15.7 | 15.5 | 15.3 | 15.3 | 15.5 | 15.3 | 14.7 | 13.6 | 12.9 |

Table 11 (page 26)

| North Lat | Jan. | Feb. | Mar. | Apr. | May | Jun. | Jul. | Aug. | Sept. | Oct. | Nov. | Dec. |
|---|---|---|---|---|---|---|---|---|---|---|---|---|
| 15 | 11.6 | 11.8 | 12.0 | 12.3 | 12.6 | 12.7 | 12.6 | 12.4 | 12.1 | 11.8 | 11.6 | 11.5 |
| 10 | 11.8 | 11.9 | 12.0 | 12.2 | 12.3 | 12.4 | 12.3 | 12.3 | 12.1 | 12.0 | 11.9 | 11.8 |

Table 16 (page 28)

| | Rhmax=60% | | | | Rhmax=90% | | | |
|---|---|---|---|---|---|---|---|---|
| Rs (mm/day) | 3 | 6 | 9 | 12 | 3 | 6 | 9 | 12 |
| Uday (m/sec) | Uday / Unight = 2.0 | | | | | | | |
| 0 | 0.96 | 0.98 | 1.05 | 1.05 | 1.02 | 1.06 | 1.10 | 1.10 |
| 3 | 0.83 | 0.91 | 0.99 | 1.05 | 0.89 | 0.98 | 1.10 | 1.14 |
| 6 | 0.70 | 0.80 | 0.94 | 1.02 | 0.79 | 0.92 | 1.05 | 1.12 |
| 9 | 0.59 | 0.70 | 0.84 | 0.95 | 0.71 | 0.81 | 0.96 | 1.06 |
| | Uday / Unight = 1.0 | | | | | | | |
| 0 | 0.96 | 0.98 | 1.05 | 1.05 | 1.02 | 1.06 | 1.10 | 1.10 |
| 3 | 0.78 | 0.86 | 0.94 | 0.99 | 0.85 | 0.92 | 1.01 | 1.05 |
| 6 | 0.62 | 0.70 | 0.84 | 0.93 | 0.72 | 0.82 | 0.95 | 1.00 |
| 9 | 0.50 | 0.60 | 0.75 | 0.87 | 0.62 | 0.72 | 0.87 | 0.96 |

សំគាល់ : ទំព័រក្នុងវង់ក្រចកបានបង្ហាញការស្រោចស្រព និង ដោះទឹកចេញ FAO ឯកសារ 24

### 13.4.3 តំរូវការទឹកស្រោចស្រពមិនសមរម្យ

តំរូវការទឹកស្រោចស្រព បានគណនាដោយសមីការខាងក្រោម :

$$IWR = (NIWR_{paddy} \times A_{paddy} / Ef_{paddy} + NIWR_{uplandcrop} \times A_{uplandcrop} / Ef_{uplandcrop}) / 100{,}000$$

ដែល IWR: តំរូវការទឹកស្រោចស្រពសុទ្ធ (លានម៉ែត្រគូប) (MCM)

NIWR: តំរូវការទឹកស្រោចស្រពសុទ្ធ (មម)

A : ផ្ទៃដីដាំដុះ (ហិចតា)

Ef : ប្រសិទ្ធិភាពស្រោចស្រព

ប្រសិទ្ធិភាពការស្រោចស្រពស្រូវ (Ef) បានយកគឺ 0.5 ទៅ 0.6 និង (Ef) សំរាប់ដំណាំគឺ 0.5 ទៅ 0.55 ។ ប្រសិនបើផ្ទៃដីស្រោចស្រពតិចជាង 100 ហិចតា ហើយប្រតិបត្តិការអាចអនុវត្តន៍ទៅបានពេលថ្ងៃ ប្រសិទ្ធិភាពអាចស្រោចស្រពបានក៏រិតខ្ពស់អាចយកបានក្នុងចំនួនប៉ាន់ស្មាននៃតំរូវការទឹកស្រោចស្រព ។

### 13.4.4 តំរូវការគណនានៃតំរូវការទឹកស្រោចស្រព

តារាង 13.2 បង្ហាញឧទាហរណ៍នៃការគណនាតំរូវការទឹកស្រោចស្រព ។

## 13.5 តុល្យភាពទឹក ~ ប្រតិបត្តិការអាងទឹក

ការគណនាតុល្យភាពទឹករវាងធនធានទឹកដែលមានស្រាប់ និង តំរូវការទឹកស្រោចស្រពគឺត្រូវបានធ្វើឡើងដើម្បីធ្វើការប៉ាន់ស្មានតំបន់ដែលអាចត្រូវបានស្រោចស្រពដោយធនធានទឹក ។ កត្តាចំបងនៃការគណនាលើតុល្យភាពទឹកគឺ ការហូរចេញពីទឹកទន្លេ តំរូវការទឹកស្រោចស្រព ចំណុះនៃការស្តុកទឹក ការបាត់បង់រំហួតរបស់អាងទឹក ។ល។ ដូចដែលត្រូវបានបង្ហាញខាងក្រោម :




តុល្យភាពទឹកគឺបង្ហាញតាមរយៈសមីការដូចខាងក្រោម

$$IN + R = IWR + EV + P + SPILL + \Delta S$$

ដែល IN: រំហូរចូលនៃទឹក

R: រំហូរចូលទឹកភ្លៀងដោយផ្ទាល់ទៅក្នុងអាងទឹក

IWR: ការផ្គត់ផ្គង់ទឹក

EV: រំហួតដែលបាត់បង់ចេញពីអាងទឹក

P: ការហូរជ្រាបដែលបាត់បង់ចេញពីអាងទឹក

SPILL: ទឹកដែលហូរធ្លាក់ចុះលើស

$\Delta S$: មាឌផ្ទុកដែលផ្លាស់ប្តូរ

### 13.5.1 ការលើកឱ្យខ្ពស់នៃអាងស្តុកទឹក

ប្រការសំខាន់សំរាប់តុល្យភាពទឹក ការរៀបចំគ្រោងដំបូងនៃអាងទឹក និង ទំនប់ទឹកត្រូវតែបានធ្វើឡើង។ នៅក្នុងការគ្រោង ផ្នែកខាងក្រោមនឹងត្រូវបានសំរេចចិត្ត ។

(i) ការលើកកំពស់របស់ទំនប់ទឹក (ii) ករិតទឹកជំនន់ និង ទឹកឡើងខ្ពស់ (iii) ករិតទឹកទាប និង (iv) ការលើកកំពស់តំបន់ស្តុកទឹក និង ខ្សែកោងមាឌនៃការលើកកំពស់តំបន់ស្តុក ។

ការគ្រោងលើការលើកកំពស់ទំនប់ទឹកឱ្យខ្ពស់ គឺជាទូទៅត្រូវបានកំណត់ដែលជាហេតុនាំឱ្យការលើកកំពស់ទំនប់ទឹកឱ្យខ្ពស់នាពេលបច្ចុប្បន្នមិនគួរត្រូវបានផ្លាស់ប្តូរធំធេងពេកទេ ។ ប្រសិនបើចំណុះនៃការផ្ទុកទឹកអាចត្រូវបានកើនឡើងគួរឱ្យពិចារណា ដោយលើកកំពស់ទំនប់ទឹកតែបន្តិចដោយពុំមានបញ្ហាធ្ងន់ធ្ងរនៅក្នុងសង្គម និង បញ្ហាវិស្វកម្ម ទំនប់ទឹកដែលខ្ពស់ជាងនេះគួរតែអាចត្រូវបានពិចារណាផងដែរ ដែលជាផ្នែកមួយផ្សេងទៀតនៃការធ្វើឱ្យប្រសើរឡើងវិញ ។

ចំណុះនៃការផ្ទុកទឹកខាងក្រោមគឺត្រូវបានកំណត់សំរាប់កករល្បាប់ និង មាឌដែលត្រូវការគឺគ្រាន់តែគណនាជាលទ្ធផលរបស់អត្រាកករល្បាប់ជាក់លាក់មួយ និង ផ្ទៃរងទឹកភ្លៀង ។ មាឌរបស់វានឹងត្រូវបានប៉ាន់ស្មានដោយពឹងផ្អែកទៅលើបទពិសោធន៍នៃកករល្បាប់ដែលមាននៅក្នុងអាងទឹកភាក់ និង មាឌរបស់កករល្បាប់ដែលត្រូវបានយល់ព្រមដោយគំរោងជាច្រើនដែលស្ថិតនៅក្បែរប្រព័ន្ធ ។ យោងទៅតាមគំរោងពីអតីតកាលនៅតំបន់ដីទាប 0.1 មម/គម$^2$ /ឆ្នាំ គឺត្រូវបានស្មើរ។

គំរូវនៃខ្សែកោងតំណាងមាឌ និង ផ្ទៃផ្ទុកទឹកគឺបានបង្ហាញដូចរូបខាងក្រោម :




រូបភាព. ខ្សែកោង ផ្ទៃ និង មាឌ

## 13.5.2 លក្ខខណ្ឌនៃការគណនា

ការគណនាតុល្យភាពទឹកសំរាប់ប្រព័ន្ធស្តុកទឹកមួយរវាងធនធានទឹកដែលមានស្រាប់ ហើយ តំរូវការទឹកសំរាប់ស្រោចស្រពគឺត្រូវបានបង្ហាញនៅក្នុងរូបភាពខាងក្រោម :




**រូបភាព. ដំណើរការគណនាតុល្យភាពទឹក**

លក្ខខ័ណ្ឌ និង ការប៉ាន់ស្មានសំរាប់ការគណនាតុល្យភាពទឹកត្រូវបានសង្ខេបដូចខាងក្រោម :

(1) រយៈពេលនៃការគណនាគួរតែមានរយៈពេលវែងតាមដែលអាចធ្វើបាន ។ តំបន់ដែលអាចស្រោចស្រពទឹកបានចំនួន 80%ដែលអាចយកជាការបាន ឬ ការទទួលទឹកមានការធ្លាក់ចុះ គួរតែត្រូវបានប៉ាន់ស្មានចំនួនមួយដងក្នុងរយៈពេល 5 ឆ្នាំ ។ ដូច្នេះរយៈពេលនៃការគណនាគួរតែត្រូវបានធ្វើឡើងយ៉ាងហោចណាស់ក្នុងរយៈពេល 15 ឆ្នាំ ។

(2) ដំណើរការនៃការគណនា នឹងត្រូវធ្វើឡើងកន្លះខែម្តងដោយពឹងផ្អែកជាមូលដ្ឋានលើទិន្នន័យដែលមាន ។

(3) ការប៉ាន់ស្មានលើការធ្លាក់ចុះរបស់ទឹកភ្លៀងជារៀងរាល់ខែ នឹងត្រូវបានបែងចែកទៅក្នុងការធ្លាក់ចុះរបស់ទឹកភ្លៀងរយៈពេលកន្លះខែម្តង ។

(4) ការវាយតំលៃទៅលើលទ្ធផលនៃការគណនា : ចំនួនដងនៃការស្រោចស្រពទឹកដែលបានធ្លាក់ចុះត្រូវបានរាប់បញ្ចូល ។ ជាគោលការណ៍ N/5 ដងនៃការធ្លាក់ចុះរបស់ទឹកក្នុង N ឆ្នាំ សំរាប់ដំណាក់នីមួយៗត្រូវបានចាត់ទុកថា ការស្រោចស្រពទឹកអាចធានានឹងគ្របដណ្តប់តំបន់ស្រោចស្រពចំនួន 80 % ដែលអាចយកជាការបាន ។

(5) **រំហួតទឹកបាត់បង់ចេញពីអាងស្តុកទឹក :**

អត្រានៃការរំហួតគឺតែងតែត្រូវបានប៉ាន់ស្មានថាមានដល់ 90% នៃ ETo ។ នៅក្នុងអាងស្តុកទឹកដ៏រាក់នេះ ការបាត់បង់រំហួតគឺជាមូលដ្ឋានគន្លឹះនៅក្នុងតុល្យភាពទឹក ។ ការបាត់បង់រំហួត គឺសមាមាត្រ

ទៅនឹងផ្ទៃទឹកដែលផ្លាស់ប្តូរនៅពេលដែលគិតទឹក ឬ មាឌផ្ទុកផ្លាស់ប្តូរ ។ ការត្រលប់ក្រោយរបស់សមីការសំរាប់ការគណនាផ្ទៃទឹក ពីមាឌផ្ទុកគួរតែរួមបញ្ចូលទៅក្នុងការគណនាតុល្យភាពទឹក ។

ប្រសិនបើតំបន់ផ្ទុក និង ខ្សែកោងមាឌមិនអាចត្រូវបានគូសដោយផ្អែកលើផែនទីលំអិតទេ ការបាត់បង់រំហួតទឹកនឹងត្រូវបានប៉ាន់ស្មានដោយធ្វើការបែងចែកជា 3 ដំណាក់កាលដូចខាងក្រោម :

- មាឌស្តុក >= ចំណុះផ្ទុកពេញ ពេលនោះ សមីការ = XX MCM/កន្លះខែ
- ចំនុះផ្ទុកពេញ > មាឌស្តុក > 0 ពេលនោះ សមីការ = xxx MCM/ កន្លះខែ
- មាឌស្តុក <= 0 ពេលនោះ សមីការ = 0

**(6) ការបាត់បង់ដោយជ្រាបទឹកពីអាងស្តុកទឹក**

អត្រានៃការជ្រាបទឹកហាក់បីដូចជាតូច បើប្រៀបធៀបជាមួយនឹងរំហួតទឹក ។ ចំនួនតូចខ្លះ ឧទាហរណ៍ 0.5 មម/1ថ្ងៃ គួរតែត្រូវបានពិចារណាសំរាប់អាងស្តុកទឹករាក់ដែលមាននៅក្នុងវាលស្រែ ។ ការបាត់បង់ដោយការជ្រាបគឺត្រូវបានប៉ាន់ស្មានផងដែរថាសមាមាត្រទៅនឹងក្រឡាផ្ទៃទឹក ។ ដូច្នេះការបាត់បង់គួរតែត្រូវបានគណនាដោយសមីការត្រលប់ក្រោយសំរាប់គណនាតំបន់ក្រឡាផ្ទៃទឹកពីមាឌស្តុក ។

**(7) ការហូរចូលទឹកភ្លៀងដោយផ្ទាល់ទៅក្នុងផ្ទៃទឹករបស់អាងស្តុកទឹក**

ទឹកភ្លៀងដែលហូរចូលដោយផ្ទាល់ទៅក្នុងផ្ទៃទឹករបស់អាងស្តុកទឹក គឺពុំត្រូវបានពិចារណានៅក្នុងការសិក្សាតុល្យភាពទឹកជាទូទៅទេ ពីព្រោះផ្នែកខ្លះរបស់ទឹកភ្លៀងត្រូវបានរួមបញ្ចូលទៅក្នុងការហូរចេញ ។ ក្នុងករណីដែលតំបន់ជុំវិញអាងស្តុកទឹកគ្របដណ្តប់ផ្ទៃរងទឹកភ្លៀងដោយអត្រាខ្ពស់ជាង 10% វាអាចត្រូវបានរួមបញ្ចូលទៅក្នុងការគណនាលំនឹងរបស់ទឹក ។

(8) ក្នុងករណីដែលទំនប់ទឹកតូចផ្សេងៗគ្នា ដែលពុំមានចំនុះផ្ទុកទឹក ចំនួនទឹកជំនន់ភាគច្រើនហូរកាត់ទំនប់កាត់ទន្លេ ហើយ មិនអាចត្រូវបានបង្វែរបានទេ ។ ដូច្នេះនៅក្នុងការគណនាតុល្យភាពទឹក ធនធានទឹកដែលមានស្រាប់គួរតែត្រូវបានប៉ាន់ស្មានដោយអត្រាមិនស្មើគ្នាជាក់លាក់ ដូចដែលបានពន្យល់នៅក្នុងផ្នែក 11.1 "ភាពដែលអាចមានទឹក" ។

### 13.5.3 គំរូការគណនា

គំរូនៃការគណនាតុល្យភាពទឹកគឺបានបង្ហាញក្នុងតារាង 13.3

## 13.6 ផែនការប្រព័ន្ធស្រោចស្រព

នៅក្នុងផ្នែកនេះ ផែនការដំណើរការសំរាប់ស្តារ និង ជួសជុលឡើងវិញសំខាន់ប្រព័ន្ធស្រោចស្រពខ្នាតមធ្យម និង ធំដូចបានរៀបរាប់ ។ ផែនការដំណើរការបានទទួលយកសំរាប់គំរោងជួសជុលឡើងវិញប្រព័ន្ធស្រោចស្រព ផ្នែកខាងលើស្ទឹងស្លាគូ (USP) គឺជារឿយៗសំអាងលើឧទាហរណ៍ ។

### 13.6.1 ការបង្កើតឡើងនៃប្រព័ន្ធស្រោចស្រព

ប្រព័ន្ធខ្នាតមធ្យម និង ខ្នាតធំដូចជា USP ប្រកបឡើងតាមការរៀបរាប់ការបង្កើតឡើងនៃប្រព័ន្ធ :

- ប្រព័ន្ធបង្វែរទឹក ( សំណង់ទ្វារទឹក សំណង់បង្ហូរចូលសេរី អាងទឹក ប្រឡាយបង្វែទឹក) ។
- ប្រព័ន្ធផ្ទេរ និង បែងចែកទឹក ( ប្រឡាយមេរង និង ប្រឡាយស្រោចស្រព) និង
- ការអនុវត្តន៍ប្រព័ន្ធទីវាល ( ផ្លូវទឹក) ។

សំរាប់ USP អាងទឹកទំនប់លោក គឺបានប្រើប្រាស់ចំបងតាមសំណង់បង្វែរទឹកដែលអាងទឹកខ្លួបត្របែកជាច្បាប់នៃ សំណង់រក្សាទឹកទុក ។

## 13.6.2 ប្រព័ន្ធបង្វែរទឹក

### (1) ប្រភេទនៃប្រព័ន្ធបង្វែរទឹក

ក្នុងគំរោងការស្តារ និង ស្ថាបនាឡើងវិញ ប្រព័ន្ធបង្វែរទឹកដើមគួរតែបានធ្វើការពិនិត្យឡើងវិញ ។ សំណង់បង្វែទឹកគួរតែបានសំរេចចិត្តពិតប្រាកដ ប្រព្រឹត្តទៅតាមចរិកលក្ខណៈនៃប្រភពទឹក ។ ប្រសិនបើរំហូរឋិតថេរ ហើយគ្រប់គ្រាន់សំរាប់សំណើ ផ្ទៃដីស្រោចស្រព ហើយផ្លូវទឹកធំៗមិនបានផ្លាស់ប្តូរទៅក្នុងផ្លូវទឹកទន្លេពេញ ! ឆ្នាំ សំណង់បង្ហូរទឹកចូលសេរីប្រហែលជាការបង្វែរទឹកដ៏ប្រសើរតាមសំណង់បង្ហូរទឹកចូល ។

ប្រសិនបើរំហូរឋិតថេរ ហើយគ្រប់គ្រាន់សំរាប់ផ្ទៃដីស្រោចស្រព ប៉ុន្តែ ចលនានៃផ្លូវទឹកនាំទឹកទៅក្នុងទន្លេ សំណង់បង្ហៀរមួយគួរតែបានសាងសង់កាត់ទទឹងទន្លេ ។ សំណង់ទ្វារទឹកដែលមានសំណង់បង្វែរទឹកប្រកបឡើងដោយបង្ហៀរ និង សំណង់បង្ហូរទឹកចូលប្រសិនបើមាឌរំហូរមានរយៈពេលយូរ គ្រប់គ្រាន់ ប៉ុន្តែរយៈពេលផ្លាស់ប្តូរជានិច្ចនៃព្រំដែនរំហូរ ផ្ទៃដីស្រោចស្រព អាងទឹក ឬ ទំនប់ត្រូវបានស្នើរឡើង ។

### (2) សំណង់បង្ហូរចូលសេរី



រូបភាព: សំណង់បង្ហូរទឹកចូល

សំណង់បង្ហូរចូលសេរីប្រកបឡើងដោយ សំណង់ទ្វារបង្ហូរចូល និង ប្រឡាយ ។ សំណង់បង្ហូរចូលសេរីមានគុណសម្បត្តិល្អដោយសារតំលៃសាងសង់ទាប ប៉ុន្តែត្រូវការចរន្តទឹកឋិតថេរទាំងពីរគឺទីតាំង និង បរិមាណក្នុងរយៈពេលតែមួយ ។ សំណង់បង្ហូរចូលសេរីត្រូវការរាយការណ៍ពីប្រតិបត្តិការទ្វារទឹក ដើម្បីជៀសវាងកករល្បាប់ក្នុងអំឡុងរយៈពេលទឹកជំនន់ទន្លេ និង កករល្បាប់ជុំវិញទ្វារទឹក ។ ទីតាំងសមរម្យសំរាប់សំណង់បង្ហូរចូលសេរី ត្រូវបានពិចារណាព្រំដែនពិតក្នុងប្រទេសកម្ពុជា ពីព្រោះកំរិតកំពស់រំហូរទឹកទន្លេផ្លាស់ប្តូរជានិច្ច ហើយ កំរិតកំពស់ទឹកមិនអាចថែទាំបានដោយគ្មានសំណង់ត្រួតពិនិត្យកាត់ទន្លេ ។

(3) **សំណង់ទ្វារទឹក**

សំណង់ទ្វារទឹកប្រកបឡើងដោយ ទំនប់បង្វៀរកាត់ទទឹងទន្លេ សំណង់ទ្វារបង្ហូរទឹកចូល និង ទ្វារបង្ហូរដើម្បីដោះកករល្បាប់ជុំវិញទ្វារបង្ហូរទឹកចូល ។ កករល្បាប់រងចុះ ហើយអាងទឹកគ្មានកករសំរាម ការសាងសង់នៅចំនុចចាប់ផ្តើមនៃប្រឡាយ ជៀសវាងការជ្រៀតជ្រែកចូលនៃកករល្បាប់ក្នុងប្រឡាយ ។ របាំងគឺជាប្រភេទមួយនៃសំណង់ទ្វារទឹក ដែលមានសើរីទ្វារកាត់ទន្លេជំនួសទំនប់ បង្វៀរថេរ ។



**Figure Headworks**

សំណង់ទ្វារទឹក មិនមានសមត្ថភាពរក្សាទឹក ហើយ តុល្យភាពទឹកគួរតែប្រព្រឹត្តទៅលើមូលដ្ឋានដែលអាចរកបានរំហូរនៃទន្លេ ។ ទោះបីជាយ៉ាងណា ទឹកឡើងជាក់ស្តែងផ្នែកខាងលើ គួរតែបានវិភាគដោយយោងតាមគ្មានសណ្ឋានវិភាគរំហូរ ដូច្នេះផ្ទៃជំនន់ផ្នែកខាងលើត្រូវបានប៉ាន់ស្មាន ។

(4) **អាងទឹក**

ក្នុងករណីទូទៅ " អាងទឹក " បានកំណត់ដោយទំនប់ដែលកំពស់របស់វាទាបជាង 15 ម. ។ ក្នុងប្រទេសកម្ពុជា អាងទឹកជាច្រើនមានភ្លឺទំនប់ពីសំភារៈក្នុងស្រុកដូចគ្នា ហើយកំពស់ទាបជាង 10 ម. ។ ជំរៅទឹកជាក់ស្តែងដែលអាចរកបានសំរាប់ការស្រោចស្រពទាបជាង 1.0 ម. ក្នុងអាងទឹកជាច្រើន ។ មុខងារដែលជឿជាក់បាននៃអាង ទឹកគឺបំពេញការស្រោចស្រព និង បទបញ្ជាទឹកហូរក្នុងរដូវភ្លៀង ។

(5) **ប្រឡាយបង្វែរទឹក**

ប្រឡាយបង្វែរទឹកនាំទឹកទៅកាន់ផ្ទៃដីស្រោចស្រព ។ ក្នុងករណីទូទៅ គ្មានសំណង់បង្ហូរទឹកចេញបានសាងសង់លើប្រឡាយបង្វែរទឹក ។ ប្រឡាយបង្វែរទឹកដែលភ្ជាប់ប្រភពទឹកទៅនឹងអាងទឹកផ្នែកខាងលើគួរតែមានសមត្ថភាពគ្រប់គ្រាន់ដើម្បីនាំទឹកទៅកាន់អាងយ៉ាងឆាប់រហ័ស ។ សមត្ថភាពនៃប្រឡាយបង្វែរទឹកគួរតែបាន សំរេចចិត្តពិតប្រាកដលើមូលដ្ឋាននៃការចំលងតាមការប្រតិបត្តិរបស់អាងទឹក ដូចបានអធិប្បាយក្នុងផ្នែក 13.5 ។

### 13.6.3 ការឆ្លងកាត់ និង ប្រព័ន្ធបែងចែកទឹក

ប្រព័ន្ធប្រឡាយស្រោចស្រពមួយជាទូទៅប្រកបឡើងដោយ i) ប្រឡាយមេ ii) ប្រឡាយរង iii) ប្រឡាយស្រោចស្រព ។ សំរាប់ប្រព័ន្ធប្រឡាយនីមួយៗទ្វារទឹកបង្ហូរចូល ទ្វារត្រួតពិនិត្យទឹក សំណង់ទំលាក់ទឹក

សំណង់កាត់ទទឹងប្រឡាយ ។ល។ បានធ្វើឱ្យងាយស្រួលក្នុងការរៀបចំបែងចែកទឹកបានមក ។

(1) **ប្រឡាយមេ និង ប្រឡាយរង**

ប្រឡាយគួរតែបានគ្រោងតាមរយៈការពេញចិត្តនៃល្បឿនទឹក ។ យោងតាមស្រទាប់ខាងក្នុងនៃប្រឡាយ និង សំណង់ទំលាក់ទឹក ដែលបានគ្រោង សំណង់លើប្រឡាយដែលបានរៀបរាប់ដូចខាងក្រោម :

- សំណង់បង្វែរទឹក
- សំណង់បង្ហូរចេញទៅកាន់ប្រឡាយស្រោចស្រព
- សំណង់ទំលាក់ទឹក
- សំណង់ត្រួតពិនិត្យទឹក ( ទ្វារ)
- សំណង់កាត់ទទឹងប្រឡាយ ( លូ ជលមាគ៌ា លូតូចៗ ឬ លូជ្រុង)
- សំណង់លូបង្ហូរកាត់ទទឹង
- ស្ពាន ( ស្ពានលើផ្លូវប្រឡាយ លើភ្លឺប្រឡាយ)
- សំណង់បង្ស្បៀរ
- សំណង់បង្ហូរចូលពីសំណង់លូបង្ហូរកាត់ទទឹង និង
- ផ្លូវសំរាប់ត្រួតពិនិត្យ

ប្រឡាយមេជាទូទៅ ត្រូវបានគ្រោងក្នុងការបែងចែកទឹកស្រោចស្រពសំរាប់ 24 ម៉ោង ។

សមត្ថភាពនៃប្រឡាយរងគឺបានសំរេចចិត្តពិតប្រាកដតាមឯកតាតំរូវការទឹកស្រោចស្រព និង កាលវិភាគទឹក ។ ក្នុងករណីនេះដែរ " ការស្រោចស្រពសារចុះសារឡើង " គឺបានរៀបចំសមត្ថភាពក្នុងការបែងចែកឱ្យបានទូលំទូ លាយទៅនឹងសេចក្តីត្រូវការមាឌទឹកជាមួយពេលវេលាកំណត់ ។

(2) **ផ្នែកប្រឡាយស្រោចស្រព**

ផ្នែកប្រឡាយស្រោចស្រពគួរបានរៀបចំ និង គ្រោងដាក់បញ្ចូលក្នុងការពិចារណាតាមអ្វីៗដូចខាងក្រោម

- ទំហំខ្នាត ( ផ្ទៃដី) នៃផ្នែកប្រឡាយស្រោចស្រពគួរតែតិចជាង 50 ហិចតា ។
- ផ្នែកប្រឡាយស្រោចស្រពនីមួយៗគួរមានមួយ ឬ ច្រើននូវសំណង់បង្ហូរចេញពីប្រឡាយរង ។
- ផ្នែកប្រឡាយស្រោចស្រពមួយគួរតែមានទីតាំងជាមួយ ឬ ជិតភូមិ
- ផ្នែកប្រឡាយស្រោចស្រពមួយគួរមានមួយ ឬ ច្រើនខ្សែប្រឡាយស្រោចស្រព និង ផ្លូវទឹក (1/4 ប្រឡាយ) បានបង្វែរទឹកពីប្រឡាយស្រោចស្រព ។
- ផ្លូវទឹកគួរគ្របដណ្តប់ផ្នែកស្រោចស្រពប្រហែល 5 ហិចតា និង
- សំណង់នៃផ្លូវទឹកគួរតែបានធ្វើដោយអ្នកទទួលផលដោយខ្លួនឯងដែលទទួលការចង្អុលបង្ហាញបច្ចេកទេសពី DOWRAM ។




រូបភាព : ផ្នែកប្រឡាយស្រោចស្រព

### 13.6.4 ការសំរេចចិត្តពីកម្រិតនៃផ្ទៃដីស្រោចស្រព

យោងតាមការប៉ាន់ស្មានផ្ទៃដីស្រោចស្រពក្នុងការសិក្សាគុណភាពទឹក ផ្ទៃដីស្រោចស្រពត្រូវបានបញ្ជាក់ក្នុងការពណ៌នាលើផែនទី ។ វាគួរបានសំគាល់ថា ផ្ទៃដីស្រោចស្រពគឺ " ផ្ទៃដីសុទ្ធ " ហៅថាផ្ទៃដីដាំដុះ ខណៈដែល " ផ្ទៃដីសមរម្យ " រួមជាមួយដីសំរាប់ប្រឡាយ ដីទួលសំរាប់ដាំដំណាំ ផ្លូវត្រួតពិនិត្យ ។ល។ ផលចែកនៃផ្ទៃដីសមរម្យសុទ្ធអាស្រ័យលើមាត្រដ្ឋាននៃផែនទី ប៉ុន្តែ 0.85 គឺភាពសមគួរបានប្រើប្រាស់សំរាប់ 1 ក្នុង 10.000 មាត្រដ្ឋានផែនទី និង 0.80 សំរាប់ 1 ក្នុង 50.000 មាត្រដ្ឋានផែនទី បន្ទាប់ពីកាត់ចោលផ្នែកមិនមែនកសិដ្ឋានលើផែនទី ។

ក្នុងការបញ្ជាក់ផ្ទៃដីស្រោចស្រព គឺរិតកំពស់ និង ការតំរង់ជាជួរនៃប្រឡាយស្រោចស្រពគួរតែបានត្រួតពិនិត្យដោយប្រុងប្រយ័ត្ន ។ ផ្ទៃដីស្រោចស្រពគួរតែតិចជាងការគ្រោងគឺរិតកំពស់ទឹកក្នុងប្រឡាយស្រោចស្រព ។ ប្រសិនបើគឺរិតកំពស់ទឹកគឺ EL. 35 ម. ផ្ទៃដីស្រោចស្រពគួរតែតិចជាង EL.34.3 ម. ដោយគិតការបាត់បង់ដោយយកចិត្តទុកដាក់ ។




រូបភាព តំបន់ស្រោចស្រពសុទ្ធ

## 13.6.5 ដ្យាក្រាមការស្រោចស្រព

ការតំរង់ជាជួរនៃប្រឡាយស្រោចស្រពគួរបានសំរេចចិត្តពិតប្រាកដ ដូចដែលបណ្តាញប្រឡាយដែលគ្របដណ្តប់ដោយបានបញ្ជាក់ផ្ទៃដីស្រោចស្រព ។ បន្ទាប់មកផ្នែកប្រឡាយស្រោចស្រពដែលបានបញ្ជាក់លើផែនទីមានផ្ទៃដីស្រោចស្រព 50 ហិចតា ឬ តិចជាងនេះ ។ ឈ្មោះ ( ក្រុម ) តំរូវការទឹកស្រោចស្រព និង ផ្ទៃដីផ្នែកប្រឡាយស្រោចស្រពនីមួយៗដែលបានចែកក្នុងប្រព័ន្ធនៃដ្យាក្រាមស្រោចស្រពដូចបានបង្ហាញខាងក្រោម :




រូបភាព ប្រព័ន្ធដ្យាក្រាមស្រោចស្រព

### 13.6.6 ការគ្រោងដំបូងនៃប្រព័ន្ធប្រឡាយ

**(1) ការគ្រោងសមត្ថភាព**

ការគ្រោងសមត្ថភាពនៃប្រឡាយស្រោចស្រពគឺបានសំរេចចិត្តពិតប្រាកដជាមួយ i) ឯកតាតំរូវការទឹកស្រោចស្រព (លីត្រ / វិនាទី / ហិចតា) ii) កាលវិភាគទឹក និង iii) ចន្លោះសេរី ។ ប្រសិនបើប្រព័ន្ធស្រោចស្រពមួយមាន 1000 ហិចតានៃផ្ទៃដីស្រោចស្រព ប្រឡាយមេគួរតែមានសមត្ថភាពសុទ្ធ 1.1 ម$^3$/វិនាទី ។ សំរាប់ក្នុងប្រព័ន្ធប្រឡាយណាមួយ "ការស្រោចស្រពសារចុះសារឡើងគឺត្រូវបានស្នើ សមត្ថភាពគួរតែបានបង្កើនដើម្បីបំពេញតំរូវការទឹកស្រោចស្រពជាមួយរយៈពេលពិតប្រាកដនៃការស្រោចស្រព។ សំរាប់ឱកាសនេះ ប្រឡាយណាមួយដែលស្រោចស្រព 10 ហិចតារៀងរាល់ 3 ថ្ងៃ ការគ្រោងសមត្ថភាពសុទ្ធ គួរតែ 3 ដង គឺ 33 លីត្រ / 1 វិនាទី" ។

**(2) ចន្លោះសេរី**

ចន្លោះសេរីនៃប្រឡាយមួយគឺបានសំរេចចិត្តពិតប្រាកដ យោងតាមចរិកលក្ខណៈនៃប្រឡាយនោះហៅថា ប្រឡាយស្រោចស្រព ប្រឡាយដោះទឹកចេញ និង សំរាប់គោលបំណងទាំងពីរ (ស្រោចស្រព និង ដោះទឹក) ។ ចន្លោះសេរីដែលបានត្រួតពិនិត្យតាមការរៀបរាប់ពីដំណើរការហើយចន្លោះសេរីធំជាងគេគួរបានរក្សាទុក ។

1) **សមីការសំរាប់ការប៉ាន់ស្មានចន្លោះសេរី**

តាមសមីការដែលបានប្រើប្រាស់ខាងក្រោម :

$$F_b = 0.05d + \beta \cdot h_v + h_w$$

ដែល $F_b$ : ចន្លោះសេរី (ម)

$d$ : ជំរៅទឹក (ម)

$\beta$ : ការផ្លាស់ប្តូរភាគរយល្បឿនទឹកទៅល្បឿនថេរ (1.0)

$h_v$ : ល្បឿនទឹក (ម) $h_v = \dfrac{v^2}{2 \cdot g}$

$h_w$ : ចន្លោះសេរីសំរាប់ការផ្លាស់ប្តូរជានិច្ចនៃផ្ទៃទឹកខាងលើ (0.15 ម)

ប្រសិនបើជំរៅទឹកគឺ 2.0 ម. ជាមួយនឹងល្បឿន 0.44 ម/វិនាទី ចន្លោះសេរីបានប៉ាន់ស្មានគឺ 0.26 ម. ។

2) **កំរិតកំពស់ទឹកសំរាប់ 120 % នៃសមត្ថភាព**

ប្រសិនបើការគ្រោងសមត្ថភាពប្រឡាយគឺ 3.5 ម$^3$/វិនាទី ជាមួយនឹងជំរៅទឹក 2.0 ម.. ហើយជំរៅទឹកសំរាប់ 4.2 ម$^3$/វិនាទី (120% នៃ 3.5 ម$^3$/វិនាទី) គឺ 2.15 ម. 0.15 ម. ដែលគោរពតាម " ចន្លោះសេរី " ។

ក្នុងករណីខាងលើចន្លោះសេរីធំជាងគេ 0.26 ម. ដែលបានរក្សាទុក ។

(3) **ទំហំខ្នាតនៃប្រឡាយ**

ទំហំនៃប្រឡាយដែលសមគួរបានសំរេចចិត្តពិតប្រាកដ ដោយវិភាគសណ្ឋានរំហូរទឹកតាមរូបមន្តរបស់ Manning ។ លំអិតបានអធិប្បាយក្នុងផ្នែករង 11.2.5 " ការគណនាជលសាស្ត្រតាមរូបមន្តរបស់ Manning" ។

ផលប្រៀបធៀបនៃជំរៅប្រឡាយទៅទទឹងបាតប្រឡាយ 0.8 ទៅ 1.0 ។ ប្រសិនបើទទឹងបាតប្រឡាយ គឺ 1.0 ម. ការគ្រោងជំរៅទឹក 1.0 ម. ឬ ទាបជាងនេះ ។ យោងតាមជំរេលមុខកាត់បណ្តោយ ផលធៀបនៃ ជំរៅទឹក ទៅកាន់ទទឹងបាតនៃប្រឡាយ និង ការគ្រោងល្បឿនទឹកដែលអនុញ្ញាតិបានអធិប្បាយក្នុងការរៀបរាប់ ទំហំ ខ្នាតនៃប្រឡាយអាចបានសំរេចចិត្តពិតប្រាកដ ។

(4) **ការគ្រោងល្បឿនទឹក**

ការគ្រោងល្បឿននៃប្រឡាយ ដែលបានសំរេចចិត្តពិតប្រាកដប្រព្រឹត្តទៅលើសំណង់នៃប្រឡាយ ដែលបានធ្វើ ឱ្យស្របគ្នាតាមលក្ខណៈវិនិច្ឆ័យ ។

1) **ល្បឿនមធ្យម**

ល្បឿនហូរមធ្យមគឺបានសំរេចចិត្តពិតប្រាកដសំរាប់កើតឡើងជាច្រើនដើម្បីធារទឹកក្នុងប្រឡាយ ។ សំរាប់ប្រឡាយស្រោចស្រព ការគ្រោងធារទឹកសំរាប់រយៈពេលស្រោចស្រពធម្មតា (0.6 ទៅ 1.0 លីត្រ/វិនាទី/ហិចតា) ដែលបានរក្សាទុកសំរាប់ការសំរេចចិត្តពិតប្រាកដនៃល្បឿនមធ្យម ។ ធារទឹក មធ្យមដែលអនុញ្ញាតិឱ្យបានគឺការប្រុងប្រយ័ត្នកករល្បាប់ និង ត្រួតពិនិត្យសំរាម 0.45 ម/វិនាទី ប្រសិនបើការងារថែទាំ (កករល្បាប់ និង សំរាមដែលបានយកចេញ) ដោយសង្ឃឹមលើអ្នកប្រើ ប្រាស់ទឹក។

2) **ល្បឿនអតិបរមា**

ល្បឿនអតិបរមាដែលបានអនុញ្ញាតិគឺបានត្រួតពិនិត្យសំរាប់ការគ្រោងធារទឹកអតិបរមា ល្បឿន អតិបរមាដែលបានអនុញ្ញាតិគឺបានបង្រួមតាមតារាងដូចខាងក្រោម :

**តារាង: ល្បឿនទឹកអតិបរមាដែលអនុញ្ញាតិបាន.**

| ប្រភេទនៃប្រឡាយ | ល្បឿន (ម/វិនាទី) |
|---|---|
| ប្រឡាយដី (ដីខ្សាច់) | 0.45 |
| ប្រឡាយដី (ខ្សាច់ល្អ) | 0.60 |
| ប្រឡាយដី (ដីល្អ) | 0.70 |
| ប្រឡាយដី (ដីល្បាយឥដ្ឋល្អ) | 0.90 |
| ប្រឡាយដី (ដីល្បាយឥដ្ឋ) | 1.00 |
| ប្រឡាយដី (ដីល្បាយឥដ្ឋលាយខ្សាច់) | 1.20 |
| បេតុងក្រាស់ (0.18 ម.) | 3.00 |
| បេតុងស្តើង (0.10 ម.) | 1.50 |
| រៀបឥដ្ឋ | 1.50~2.00 |
| ឥដ្ឋសើម | 2.50 |
| បេតុងល្អ | 3.00 |

(5) **ការបាត់បង់នៃជលសាស្ត្រ**

ការបាត់បង់ផ្សេងៗគួរបានពិចារណាក្នុងការគ្រោងនៃប្រព័ន្ធប្រឡាយក្នុងទំរង់នៃ"ដើមហេតុការបាត់បង់" ក៏រិតកំពស់ទឹកពិតប្រាកដក្នុងប្រឡាយ ។

1) **ការបាត់បង់ដោយកកិត**

ដើមហេតុការបាត់បង់ដោយកកិតគឺបានប៉ាន់ស្មានដោយរូបមន្ត Manning ខាងក្រោម :

$$h_f = \frac{Q^2 \cdot l}{2}\left(\frac{n_1^{\ 2}}{R_1^{\ 4/3} \cdot A_1^{\ 2}} + \frac{n_2^{\ 2}}{R_2^{\ 4/3} \cdot A_2^{\ 2}}\right) = \frac{1}{2}\left(\frac{n_1^{\ 2} \cdot V_1^{\ 2}}{R_2^{\ 4/3}} + \frac{n_2^{\ 2} \cdot V_2^{\ 2}}{R_2^{\ 4/3}}\right) \cdot l$$

ដែល,

Q : ធារទឹក (ម$^3$/វិនាទី)

A : ផ្ទៃរំហូរ (ម$^2$)

$h_f$ : ដើមហេតុការបាត់បង់ដោយកកិត (ម)

l : ចំងាយរវាងផ្នែក (ម)

R : កាំនៃជំរៅ (ម)

n : មេគុណកកិត

V : ល្បឿនមធ្យម (ម/វិនាទី)

2) **ការបាត់បង់ផ្សេងៗ**

ដើមហេតុការបាត់បង់ផ្សេងៗដូចបញ្ជីខាងក្រោម គួរបានពិចារណា

- ដើមហេតុការបាត់បង់នៅសំណង់ និង បង្ហូរចេញ
- ដើមហេតុការបាត់បង់ពេលឆ្លងកាត់
- ដើមហេតុការបាត់បង់ដោយរបាំង
- ដើមហេតុការបាត់បង់ដោយស្ពានលយទៅក្នុងទឹក
- ស្ពានលយកោងទៅក្នុងទឹក

តាមរយៈការបាត់បង់ជាច្រើនខាងលើពី 0.02 ម. ទៅ 0.05 ម. នៃដើមហេតុការបាត់បង់សំរាប់ទីតាំង និង សំណង់ទីមួយៗ ។ សំរាប់សំណង់ធំ ហើយ ប្រឡាយមានល្បឿនទឹកខ្ពស់ ការបាត់បង់នៃជលសាស្ត្រ គួរបានធ្វើការគណនា ប៉ុន្តែសំរាប់ប្រព័ន្ធប្រឡាយតូចៗ 0.02 ទៅ 0.05 ម. ដើមហេតុការបាត់បង់ អាចបានរក្សាទុកលើទីតាំង ឬ សំណង់ដូចបានអធិប្បាយខាងលើ ។

## 13.7 ប្រព័ន្ធស្រោចស្រពនៃតំបន់អាងខ្នាតតូច :

### 13.7.1 ស្ថានភាពទូទៅ

ប្រព័ន្ធនៃតំបន់ស្រោចស្រង់ អាងខ្នាតតូចដូចជា កម្មវិធីនៃតំបន់អាងខ្នាតតូច ដែលមានសមាសធាតុដូចតទៅ :

- អាង ( បរិមាណដែលត្រូវចាត់ចែង)
- ប្រព័ន្ធប្រឡាយ ( ប្រឡាយចែកចាយ)



រូបភាព. សមាសធាតុនៃអាង

សំរាប់គ្រប់ប្រព័ន្ធស្រោចស្រពនៃតំបន់អាងខ្នាតតូច ផ្ទៃដីស្រោចស្រពដែលមាន ស្រាប់នៃបរិមាណតុល្យភាពស្រោចស្រព ដែលជាប្រភពទឹកនៃប្រព័ន្ធស្រោចស្រព ដែលធំជាងដទៃទៀត ។ ដូច្នេះការអភិវឌ្ឍន៍ប្រព័ន្ធប្រឡាយ នៃប្រព័ន្ធស្រោចស្រពតំបន់អាងខ្នាតតូចដែលជាការស្រូបយកដោយអ្នកដែលបានទទួលផលប្រយោជន៍ ។

នៅក្នុងក្បួនណែនាំនេះ អាងគឺជាការកំណត់ដូចជា " អាងមួយជាមួយទំនប់ដី ដែលមានកំពស់តិចជាង 10 ម. "

សំណង់នៃអាងទំនប់ទាំងអស់ដែលមានគឺ សំណង់បង្ហៀរ សំណង់ស្អាក់ទឹក សំណង់បញ្ចូលទឹក និង សំណង់ដទៃទៀត ។ល។

### 13.7.2 គំរោងផែនការ

គំរោងការលំអិតនៃការស្តារ និង កសាងឡើងវិញនៃអាងទឹកគួតែនៅក្រោម ដំណើរការប្រសិទ្ធិភាពមួយ យោងលើការពិភាក្សាល្អិតល្អន់ជាមួយនឹងការងារដែលពាក់ព័ន្ធ ។

ដំណើរការជាស្តង់ដារមួយនៃគំរោងបួងនៃការកសាងឡើងវិញអាងទឹកបង្ហាញខាងក្រោម :




រូបភាព. ដំណើរការនៃគំរោង

(1) **ការសិក្សាស្រាវជ្រាវ**

ការសិក្សាស្រាវជ្រាវនូវអាងទឹកដែលមានស្រាប់ត្រូវតែប្រព្រឹត្តទៅតាមគំរូខាងក្រោម :

- ជំរាបនៃទំនប់
- ស្នាមបែក និង កំហូចទ្រង់ទ្រាយនៃទំនប់
- កង្វះខាតនៃកំពស់បំរុង
- អស្ថិរភាពនៃទំនាបដោយសារការសឹករិចរិល
- សំណង់បង្ហៀរគ្មានមុខងារច្បាស់លាស់
- សំណង់បង្ហូរទឹកចូលគ្មានមុខងារច្បាស់លាស់
- សំណង់ត្រួតពិនិត្យគ្មានមុខងារច្បាស់លាស់ ( ទ្វារទឹករវៃ សំណង់វាស់ធារទឹក ។ល ។ )

(2) **ការប៉ាន់ស្មានគ្រោងនៃទឹកជំនន់**

សំរាប់គ្រប់បណ្តាអាងទឹកទាំងអស់ ការគ្រោងទឹកជំនន់ជាការប្រកាន់យកនៃលទ្ធផលដែលបង្ហាញជាបន្តបន្ទាប់ដូចនេះ

1) ការវិភាគនៅលើប្រូបាប៊ីលីតេ

ប្រសិនបើទិន្នន័យធារទឹកទន្លេអាចមាន ការវិភាគនៅលើប្រូបាប៊ីលីតេ គឺជាការពន្យល់បង្ហាញក្នុងផ្នែក 11.2 ត្រូវតែប្រកាន់យកជាចាំបាច់ ។ ក្នុងរយៈពេលជាមួយគ្នានៃការគ្រោងផែនការទឹកជំនន់ (design floods) ដែលប្រកាន់យក បង្ហាញក្នុងតារាង 13.1 ។

2) បរិមាណទឹកជំនន់ធំបំផុតពីអតីតកាល

ទឹកជំនន់ធំជាងគេ ក្នុងពេលកន្លងមកអាចប៉ាន់ប្រមាណទៅលើប្រភពនៃការតាមដានទឹកជំនន់កន្លងមក ឬ ក៏ការពិនិត្យដោយប្រចាំ ។ យោងទៅលើនីវ៉ូទឹកនៃការសង្កេតធារទឹក ការគណនាធារទឹក

ដទៃទៀត ដោយការវិភាគទៅលើឯកទំរង់ហូរ ឬ ក៏មិនមែនឯកទំរង់ហូរ ។ ការសិក្សាស្ទង់ទន្លេ វាជាគំរូវការសំរាប់ការវិភាគ ។

(3) **ផែនការប្រព័ន្ធស្រោចស្រព និង ប្រព័ន្ធបោះទឹក**

ផ្ទៃដីដែលអាចស្រោចស្រពបាន នៃប្រព័ន្ធស្រោចស្រពអាងទឹកវាគឺជាការត្រួតពិនិត្យនូវភាពដូចគ្នា នៃគុណភាពទឹកនៃអាងទាំងអស់សំរាប់ឆ្នាំបន្តបន្ទាប់ ។ ភាពដូចគ្នាទាំងនេះនឹងបង្ហាញពីស្ថានភាពក្នុងរូបភាព នៃផ្នែក 13.5 "គុណភាពទឹក " ផ្ទៃដីស្រោចស្រព និង សំណង់ទាំងឡាយបានធ្វើជាគំរោងដែលបានរៀបរាប់ ក្នុងផ្នែកខាងលើ ។

## 13.7.3 ការកំណត់នូវខ្នាតប្រវែង

(1) **កំរិតកំពស់**

ការកំណត់កំរិតកំពស់គឺបានរៀបរាប់នៅក្នុងអនុផ្នែកនៃ 13.5.1 "ការកំណត់កំរិតកំពស់នៃអាងទឹក"

(2) **ទំនប់ទឹក**

សេចក្តីអធិប្បាយនៅក្នុងផ្នែក 13.2 "កំរិតគោលដៅនៃការស្តារ និង ការកសាងឡើងវិញ" ។ ទំនប់ទាំងអស់ដែលកំពស់មិនខ្ពស់ជាង 5 ម. គួរតែអនុវត្តទៅតាមស្តង់ដារដែលបានបង្ហាញនូវផ្នែកនៃទំរង់ 13.1 ។ ទទឹងរបស់ទំនប់ផ្នែកខាងលើគឺ 5 ម. និង ជើងទេរទំនប់គឺ 1:2.0~1:3.0 សំរាប់ផ្នែកនៃអាង និង 1:1.5~1:2.5 សំរាប់ផ្នែកខាងក្រៅអាង ។ ទំនប់ដែលមានស្រាប់អាចប្រើប្រាស់បាន ប្រសិនបើទំនប់នោះមានលក្ខណៈមាំមួន ។ ដើមឈើទាំងអស់ដែលនៅលើទំនប់ត្រូវតែយកចេញព្រមទាំងផ្លាស់ប្តូរនូវសំភារៈដែលមានការខូះចន្លោះទាំងអស់ ។ ដីខ្សាច់ដែលមានខ្សាច់សុទ្ធ 75% រឺក៏ច្រើនជាង និង ដីដែលមានដីឥដ្ឋ 15 % រឺក៏ច្រើនជាង អាចត្រូវប្រើប្រាស់សំរាប់ជាសំភារៈតួទំនប់ ។ ទំនប់ណាដែលកំពស់ខ្ពស់ជាង 5 ម. ត្រូវតែពិនិត្យលំអិត ដោយការវិភាគយ៉ាងហ្មត់ចត់បន្ទាប់ពីការអង្កេតនូវសំភារៈតួទំនប់ទាំងអស់នៃទំនប់ដែលមានស្រាប់ ឬ ក៏សន្និតិការប្រើប្រាស់កន្លែងជីកថ្ម ។

(3) **សំណង់បង្ហៀរ**

បរិមាណ និង ទំហំនៃសំណង់បង្ហៀរ គួរតែកំណត់ដោយអាស្រ័យលើ ការប៉ាន់ប្រមាណគំរោងការលំអិតនៃទឹកជំនន់ ។ នៅក្នុងក្បួនណែនាំនេះ ប្រភេទសំណង់បង្ហៀរ (ទឹកហូរលើក្រេស = over flow type) គឺគំរូវឱ្យដល់ ការបញ្ជៀសនូវភាពបរាជ័យនៃប្រតិបត្តិការក្នុងខណៈពេលនៃទឹកជំនន់ ។ បរិមាណធារទឹកនៃលំហូរពីលើ (overflow) សំណង់បង្ហៀរត្រូវបានគណនាតាមរូបមន្តដូចខាងក្រោមនេះ :

$$Q = CBH^{(3/2)}$$

ដែល,
C : ប្រសិទ្ធិភាពនៃធារទឹក
B : ប្រវែងទទឹងបង្ហូរនៃក្រេស (crest) (ម)
H : កំពស់បង្ហូរ (ម)

C-គឺជាតំលៃនៃកំរិតអតិប្បរមា ប៉ុន្តែសំរាប់ប្រភេទស្តង់ដារនៃសំណង់បង្ហៀរប្រភេទហូរលើក្រេស C~1,9-2,2 ។ សំរាប់សំណង់បង្ហៀរដែលមានក្រេសធំ C=1,7 អាចនឹងទទួលយកក្នុងការចាប់ផ្តើមដំបូងនៃការប៉ាន់ប្រមាណសំរាប់ការបង្កើតឡើងនូវគំរោងការលំអិតនៃទឹកជំនន់អាងទឹកទំនប់លោក (Q=420m$^3$/s) អាចនឹងបង្ហូរចេញតាមរយៈសំណង់បង្ហៀរប្រភេទហូរពីលើ (overflow type) អនុវត្តន៍ដូចតទៅ :

1) ក្នុងករណីដែលកំពស់បង្ហូរ 0.8ម. ប្រភេទហូរពីលើសំណង់បង្ហៀរ (C=2.2)

$B = Q / CH^{(3/2)} = 267$ ម

2) ក្នុងករណីដែលកំពស់បង្ហូរ 1.10 ម. ប្រភេទហូរលើសំណង់បង្ហៀរ (C=2.2)

$B = Q / CH^{(3/2)} = 165$ ម

3) ក្នុងករណីដែលកំពស់ 1.10 ម. ប្រភេទសំណង់បង្ហៀរក្រេសធំ (C=1.7)

$B = Q / CH^{(3/2)} = 214$ ម

(4) **សំណង់យកទឹកទាំងអស់ :**

សំណង់យកទឹកទាំងអស់ត្រូវតែគ្រោងលំអិតជាមួយនឹងការគ្រោងធារទឹករបស់ប្រលាយ ដែលភ្ជាប់ជាមួយអាងទឹក ។

(5) **ការថែទាំទ្វារទឹក :**

ការថែទាំទ្វារទឹកត្រូវតែដាក់បញ្ចូលសំរាប់ការរក្សាទឹកក្នុងអាងព្រមទាំងសំរាប់ការបង្ហូរចេញនៃស្ទឹង ឬទន្លេ ។ បរិមាណធារទឹកនៃទ្វារទឹកមិនត្រូវបានគណនាសំរាប់ធារទឹកជំនន់ឡើយ ។ ទ្វារទឹកត្រូវតែសាងសង់ឡើងនៅជិតប្រភពទឹកស្ទឹង ។

## 13.8 ប្រព័ន្ធស្រោចស្រពដែលប្រើប្រាស់ស្រះទឹក

### 13.8.1 លក្ខណៈទូទៅ

ប្រព័ន្ធស្រោចស្រពដែលប្រើស្រះទឹកដែលមានស្រាប់ដែលមានសមាសភាគដូចនេះ

- ស្រះ (ជាលក្ខណៈឯកជន ក្រុម រឺ ស្រះប្រឡាយ) និង
- សំណង់ពាក់ព័ន្ធ (ជណ្តើរ របង ប្រលាយយកទឹក ។ល។)

ផ្ទៃដីស្រោចស្រពដែលលាតសន្ធឹងនៅក្នុងបរិវេណនៃស្រះ និង ការយកទឹកប្រើប្រាស់គួរតែធ្វើដោយរប្បៀប ផ្សេងៗគ្នា ( ដោយប្រើប្រាស់ឧបករណ៍សាមញ្ញ រឺ ក៏ម៉ាស៊ីនបូមទឹក)

ប្រភេទនៃស្រះមាន :

- ស្រះជាក្រុម ប្រើប្រាស់ដោយក្រុមកសិករ
- ស្រះឯកជន ប្រើប្រាស់ដោយកសិករដែលជាម្ចាស់ផ្ទាល់
- ស្រះប្រឡាយសាងសង់ឡើងនៅក្នុងប្រឡាយ ( ដីសាធារណៈ)

### 13.8.2 ផែនការ

ប្រព័ន្ធស្រោចស្រពដែលប្រើស្រះ ជាទូទៅសាងសង់ឡើងនៅលើដីឯកជន ឯផែនការ និង គំរោង លំអិត ត្រូវតែប្រព្រឹត្តទៅនៅក្នុងលក្ខណៈសហការជាមួយអ្នកដែលបានផលប្រយោជន៍ ។ នៅក្នុងគំរោងដាក់សំណើ ដល់អ្នកប្រើប្រាស់នៅលើការវាស់ស្ទង់ផែនការ និង ទំរង់គំនូរបច្ចេកទេស ។

(1) **អត្តសញ្ញាណកម្ម ( ទំរង់-12 )**

ការអភិវឌ្ឍន៍ស្រះជាការដាក់សំណើ ឱ្យដល់គ្រប់នៃអ្នកភូមិ ។ សំរាប់សេចក្តីបញ្ជាក់នៃស្រះដើម្បីនឹងធ្វើការ អភិវឌ្ឍន៍ក្បួនដូចខាងក្រោមនេះ វាជាការបង្ហាញច្បាស់ :

- ភូមិសាស្ត្រ (ការសំរបសំរួល និង ផែនទី)
- ប្រភេទនៃស្រះដែលបានស្នើឡើង
- សមាជិករបស់ស្រះជាក្រុម
- ទំហំដីសំរាប់ស្រះស្រោចស្រព

អាទិភាពដើម្បីធ្វើអត្តសញ្ញាណកម្ម ការពន្យល់ និង ពិភាក្សា នឹង ត្រូវធ្វើឡើងជាមួយប្រធានភូមិ ឬ ក៏អ្នកតំណាងដទៃទៀតដូចជាប្រធានក្រុមជាដើម ។

បន្ទាប់ពីប្រមូល នូវពត៌មានសំខាន់ៗសំរាប់អត្តសញ្ញាណគំរូការពន្យល់នៅក្នុងការប្រជុំនៃគំរោងជាពិសេស ទៅលើការទទួលខុសត្រូវនៃគំរោងព្រមទាំងការចូលរួមពីអ្នកដែលទទួលផលប្រយោជន៍ទាំងអស់ត្រូវតែជាអ្នកធ្វើសំណើរ ។

(2) **ការវាស់ស្ទង់ ( ទំរង់-13 )**

ការវាស់ស្ទង់នៅលើការធ្វើស្រះ និង ផ្ទៃដីស្រោចស្រព គួរតែប្រព្រឹត្តទៅនៅលើការអង្កេតនូវចំនុចទាំងអស់ ដែលបានបង្ហាញនូវទំរង់-13 ។ បន្ទាប់ពីការសិក្សាវាស់ស្ទង់ ការចាប់ផ្តើមដំបូងនៃគំរោងលំអិតត្រូវតែប្រព្រឹត្តទៅភ្លាមៗដើម្បីនឹងពន្យល់លើគោលការណ៍សំខាន់ៗ នៃការសាងសង់ចំពោះអ្នកដែលបានទទួលផលប្រយោជន៍ ។ បន្ទាប់មក គោលការណ៍របស់គំរោងគឺ ( ការចូលរួមរបស់អ្នកដែលបានទទួលផលប្រយោជន៍ និង ការទទួលខុសត្រូវរបស់ម្ចាស់គំរោង) ត្រូវតែបញ្ជាក់ទៅវិញទៅមក ។

ការចូលរួម និង ការទទួលខុសត្រូវរវាងម្ចាស់គំរោងនិងអ្នកដែលបានទទួលផលប្រយោជន៍ត្រូវតែសំរេចឱ្យបានត្រឹមត្រូវដោយម្ចាស់គំរោង ។

(3) **ការគ្រោង ( ទំរង់-14 )**

ការគ្រោងលំអិតស្រះត្រូវតែធ្វើឡើងបន្តបន្ទាប់នៃការផ្តល់នូវប៉ារ៉ាម៉ែត្រក្នុងទំរង់ 14 ។ ជំរៅស្រះគឺថេរ = 3 ម. ។ ដូច្នេះហើយទឹកក្នុងដីត្រូវបានបង្កើនបានខ្លះៗនូវការប្រើប្រាស់ ។ មាឌរបស់សំណង់ និង បរិមាណគួរតែគណនាអាស្រ័យលើឯកតាតំលៃ ដែលបានផ្តល់នៅក្នុងទំរង់គំរោងលំអិត ( ទំរង់- 14) ។

## 13.9 ប្រព័ន្ធដោះទឹក

### 13.9.1 លក្ខណៈទូទៅ

សេចក្ដីរៀបរាប់នៅក្នុងផ្នែក 13.2 "គំនិតគោលដៅនៃការស្ដារ និង កសាងឡើងវិញ" ការពង្រីកនូវប្រព័ន្ធដោះ ទឹកគួរតែត្រូវបានពិចារណាសំរាប់តំបន់ដែលមានទឹកច្រើន អាចនឹងប្រើប្រាស់នូវការបង្ហូរបរិមាណចេញដោយប្រព័ន្ធដោះទឹកនៅកន្លែងទាប (អូរ ស្ទឹង បឹង) ។ ប្រសិនបើបរិមាណទឹកដែលមានស្រាប់ពុំបានគ្រប់គ្រាន់ការពង្រីកនូវប្រព័ន្ធដោះទឹកគឺពុំត្រូវបានពិចារណាឡើយ ប៉ុន្តែការថែរទាំជួសជុលនូវប្រព័ន្ធដែលមានបច្ចុប្បន្នវាជាការចាំបាច់ ។ នៅក្នុងករណីនេះ តំរូវការនៃការដោះទឹកគួរតែមានតុល្យភាពទៅនឹងតំរូវការទឹកស្រោចស្រព ដូច្នេះហើយទឹកស្រោចស្រពគួរតែដោះចេញក្នុងភាពសមរម្យមួយ (ប្រហែល 1.0 លីត្រ/ហ.ត) ។

### 13.9.2 តំរូវការប្រព័ន្ធដោះទឹក

**(1) ប្រព័ន្ធបោះទឹកសំរាប់វាលស្រែ**

តំរូវការនៃប្រព័ន្ធដោះទឹកសំរាប់វាលស្រែគួរតែត្រូវពិចារណា ដើម្បីនឹងបង្ហូរចេញក្នុងរយៈពេលភ្លៀងបីថ្ងៃ ក្នុងរយៈពេល 10 ឆ្នាំប្រាកដនៃទឹកជំនន់ ។

តំរូវការដោះទឹកចេញ សំរាប់ទីវាលស្រែ ជាការគណនាសរុបនូវលក្ខខ័ណ្ឌជាបន្តបន្ទាប់ :

- ជំរៅទឹកដំបូងនៃស្រែ : 50 មម.
- ជំរៅទឹកដែលចាំបាច់ : 150 មម.
- បរិមាណទឹកក្នុងរយៈពេលដែលធ្វើឱ្យលិចលង់ 3 ថ្ងៃ
- ទឹកភ្លៀងបីថ្ងៃ ក្នុងរយៈពេល 10 ឆ្នាំក្នុងខេត្តតាកែវ 173 មម

ឯកតានៃបរិមាណទឹកដែលត្រូវដោះចេញគួរតែសំរេចដោយយកទឹកភ្លៀងបីថ្ងៃ នៃជំនន់ដែលបង្ហាញនូវរូបភាព 13.7 ។ ក្រោមលក្ខខ័ណ្ឌខាងលើឯកតានៃតំរូវការដោះទឹកត្រូវសំរេចយក 1,6 លីត្រ/វិនាទី/ហត. ។

**(2) ការបោះទឹកសំរាប់ដំណាំផ្សេងៗ**

តំរូវការដោះទឹកសំរាប់ដំណាំផ្សេងៗគួរត្រូវពិចារណានៅលើការបង្ហូរដោយទឹកភ្លៀង 1 ថ្ងៃក្នុងទិន្នន័យ 10 ឆ្នាំ ដោយពុំគិតពីការជន់លិច ។ តំរូវការដោះទឹកសំរាប់ដីដំណាំតំបន់ខ្ពស់ ឬ គណនាទៅតាមលក្ខខ័ណ្ឌដូចតទៅ :

- ជំរៅទឹកតំបូងនៅក្នុងស្រែ : 0 មម.
- ជំរៅទឹកដែលអនុញ្ញាតិ : 0 មម.
- បរិមាណទឹកក្នុងខណៈដែលធ្វើឱ្យលិចលង់ : 1 ថ្ងៃ
- ទឹកភ្លៀង 1 ថ្ងៃ ក្នុងរយៈពេល 10 ឆ្នាំ ក្នុងខេត្ត តាកែវ 113 មម.

ឯកត្តានៃតំរូវការដោះទឹក គួរត្រូវបានសំរេចយក ដូច្នេះដំណាំទាំងអស់នឹងមិនត្រូវបានលិចលង់ឡើយ ។ នៅក្នុងលក្ខខ័ណ្ឌភាគច្រើន ដំណាំត្រូវបានដាំនៅលើផ្ទៃដីស្រែក្នុងខណៈពេលដែលមុន ឬ បន្ទាប់ពីរដូវភ្លៀងព្រម

ទាំងប្រព័ន្ធដោះទឹកនៃទីវាលស្រែត្រូវតែយកមកប្រើប្រាស់ ។ ហេតុដូច្នេះហើយ វាជាការចាំបាច់ដើម្បីបញ្ចៀសទឹកជំនន់សំរាប់ដំណាំផ្សេងៗដោយការអនុវត្តន៍ជាក់ស្តែងនៅលើកសិដ្ឋានដែលឱ្យឈ្មោះថា "high ridge cultivation" រូបភាព 13.8 បង្ហាញពីដំណាំរួមផ្សំដែលដាំពូនជាជួរកំពស់ 125 មម. ដែលជាតំរូវការសំរាប់បញ្ចៀសនូវការជន់លិចជាមួយនិងឯកតាតែមួយនៃតំរូវការដោះទឹកគឺ 1,6 លីត្រ/វិនាទី/ហត. សំរាប់ការដាំស្រូវ ។

នេះជាការណែនាំការលើករងកំពស់ខ្ពស់ជាង 150 មម. ត្រូវតែប្រកាន់យកដូចបង្ហាញខាងក្រោម :




រូបភាព : ការដាំដុះពូនជារងសំរាប់មិនមែនដំណាំស្រូវ

## 13.10 ការប៉ាន់ស្មានតំលៃ

### (1) លក្ខណៈទូទៅ

ការលើកគំរោងមួយត្រូវតែអនុវត្តន៍ជាមួយនឹងការវិនិយោគថវិកាផ្ទាល់ពិតប្រាកដ របស់រដ្ឋាភិបាលកម្ពុជា ឬ ក៏ថវិកាអន្តរជាតិ ។ ការពិចារណានៅលើគំនិតនៃថវិកាសំរាប់ការអភិវឌ្ឍន៍ មធ្យោបាយសេដ្ឋកិច្ច នៅក្នុងពាក្យថាតំលៃ និង វិភាគចំណូលនឹងត្រូវធ្វើឡើងសំរាប់គ្រប់ប្រភេទនៃគំរោង ។ ដូច្នេះ តំលៃប៉ាន់ស្មានគឺជាការពិចារណាមួយដ៏សំខាន់នៅក្នុងគំរោងបួងនៃជំពូកទាំងអស់នៃការត្រួតពិនិត្យនូវ មធ្យោបាយសេដ្ឋកិច្ច ។ នៅក្នុងផ្នែកនេះ ដំណើរការនៃការប៉ាន់ស្មានតំលៃសំរាប់ការវាយតំលៃគំរោងគឺជាការវាយតំលៃគំរោងដែលបានរៀបរាប់លំអិតនៅក្នុងជំពូក 18 ។

### (2) ប្រភេទនៃគំរោង និង កិច្ចសន្យា

អាទិភាពដើម្បីនឹងប៉ាន់ស្មានតំលៃនៃប្រភពធនធានទាំងអស់ និង ដំណាក់កាលនៃការអនុវត្តន៍ត្រូវតែធ្វើការសន្មត ។ សំរាប់គំរោងធំៗដែលអនុវត្តន៍ជាមួយ និង ការប្រាក់បរទេសគួរតែធ្វើកិច្ចសន្យាជាទូទៅតាមរយៈការដេញថ្លៃជាលក្ខណៈអន្តរជាតិ (ICB) ក្នុងខណៈពេលដែលការងារសាងសង់ដែលមិនជាសំខាន់ណាស់ណាកិច្ចសន្យាគួរតែធ្វើឡើងតាមរយៈការដេញថ្លៃក្នុងលក្ខណៈជាតិ (LCB) ។ តំលៃនៃគំរោង ឬ ក៏តំលៃឯកត្តានៃការងារសំណង់នីមួយៗសំរាប់ ICB គួរតែខ្ពស់ជាង LCB ។ ដូច្នេះឯកត្តាតំលៃត្រូវតែធ្វើការសំរេចអាស្រ័យលើប្រភេទនៃកិច្ចសន្យាដែលត្រូវបានធ្វើឡើងជាមួយគំរោង ។

### (3) សមាសភាពនៃតំលៃគំរោង

តំលៃនៃគំរោង (ថវិកាហិរញ្ញវត្ថុ) សំរាប់ការប៉ាន់ស្មានតំលៃគួរតែមានសមាសភាគដូចតទៅ :

- តំលៃសាងសង់ផ្ទាល់
- តំលៃចំណាយផ្សេងៗ
- តំលៃសំភារៈបរិក្ខារ ក្នុងការប្រតិបត្តិ និង ការថែទាំ
- តំលៃលើការរុះរើគេហដ្ឋាន និង ផ្ទៃដីដែលប៉ះពាល់ក្នុងសំណង់
- តំលៃចំណាយលើរដ្ឋបាល
- តំលៃបំរើការលើផ្នែកវិស្វកម្ម
- តំលៃបំរុងសំរាប់ការប្រែប្រួលបរិមាណការងារ
- តំលៃបំរុងសំរាប់ការប្រែប្រួលនូវតំលៃទីផ្សារ ( អត្រាប្តូរប្រាក់ ពលកម្ម សំភារៈបរិក្ខារ ។ល។)

1) **តំលៃសាងសង់ផ្ទាល់**

តំលៃសាងសង់ផ្ទាល់គឺមានតំលៃទាំងអស់នៃទំហំការងារសំរាប់ការងារសំណង់ដែលរួមបញ្ចូលការដឹកចូល និង ការដឹកចេញ តំលៃគ្រឿងចក្រ កំលាំងពលកម្ម ការរៀបចំការងារទាំងឡាយ ព្រមទាំងសកម្មភាពទាំងអស់ដែលជាប់ទាក់ទង និង ការងារសាងសង់ ។ តំលៃជាទូទៅបូកសរុបដោយការងារសំណង់ទាំងអស់ដូចជាការរៀបចំការងារ អាងទឹក ប្រលាយមេ ប្រលាយរង និង ការអភិវឌ្ឍន៍នៅលើកសិដ្ឋាន ។ល។

2) **តំលៃចំណាយផ្សេងៗ**

តំលៃចំណាយផ្សេងៗគឺបូកបញ្ចូលនូវតំលៃនៃការអភិវឌ្ឍន៍ស្ថាប័ន ប្រសិនបើគំរោងមានសមាសភាគនៃការកសាងសមត្ថភាពនៃបណ្តាគំរោងទាំងនោះ ។ ប្រសិនបើការអភិវឌ្ឍន៍ស្ថាប័នត្រូវបានអនុវត្តន៍ដូចជាផ្នែកមួយនៃសេវាវិស្វកម្ម តំលៃនៃការអភិវឌ្ឍន៍ស្ថាប័នគួរតែរួមបញ្ចូលទៅក្នុងតំលៃសេវាវិស្វកម្ម ។

3) **តំលៃបរិក្ខារសំរាប់ប្រតិបត្តិការ និង ថែទាំ**

បរិក្ខារដែលចាំបាច់សំរាប់ប្រតិបត្តិការ និង ការថែទាំត្រូវតែស្វែងរកមកមុនពេលបញ្ចប់ការងារសាងសង់ទាំងអស់ ព្រមទាំងតំលៃចាំបាច់សំរាប់បរិក្ខារគួរតែបានត្រូវបូកបញ្ចូលទៅក្នុងតំលៃវិនិយោគដំបូង ។ ប្រសិនបើការងារប្រតិបត្តិការ និង ការថែទាំ ត្រូវបានធ្វើនៅលើប្រភេទនៃកិច្ចសន្យា ឬ ក៏គ្មានបរិក្ខារ ឬ ក៏មានភាពគ្រប់គ្រាន់នៃបរិក្ខារសំរាប់ប្រតិបត្តិការ និង ការថែទាំតំលៃមិនមានភាពចាំបាច់នៅក្នុងការគណនា ។

4) តំលៃនៃការរើប្តូរលំនៅដ្ឋាន និង ដីដែលប៉ះពាល់

ក្នុងករណីនេះ ការរើប្តូរលំនៅដ្ឋាន និង ផ្ទៃដីដែលប៉ះពាល់ វាជាប្រការសំខាន់សំរាប់ការអនុវត្តន៍គំរោងតំលៃត្រូវបានប៉ាន់ស្មាន ។

5) តំលៃនៃការចំណាយទៅលើការងាររដ្ឋបាល

តំលៃរដ្ឋបាលបូកសរុបជាមួយប្រាក់ខែ ព្រមទាំងប្រាក់បេសកកម្មសំរាប់បុគ្គលិកផ្នែករដ្ឋបាលរបស់គំរោង ក្នុងខណៈពេលអនុវត្តន៍គំរោង តំលៃប្រតិបត្តិការនៃសំណង់ទាំងអស់ បរិក្ខារព្រមទាំងការចំណាយ ផ្សេងៗ សំរាប់ការងារប្រតិបត្តិ ។

6) **តំលៃសំរាប់សេវាផ្នែកវិស្វកម្ម**

តំលៃសំរាប់សេវាវិស្វកម្ម បូកសរុបជាមួយនឹង តំលៃសំរាប់សិក្សាវាស់ស្ទង់ គ្រោងប្លង់ការងារត្រួតពិនិត្យ ព្រមទាំងតំលៃផ្សេងៗទៀតនៃសកម្មភាពវិស្វកម្មចាំបាច់សំរាប់ការអនុវត្តន៍គំរោង។ តំលៃសេវាវិស្វកម្ម ជាទូទៅប៉ាន់ស្មាននូវភាគរយពិតប្រាកដគឺ ~ 10% នៃតំលៃសរុបរបស់គំរោង ។

7) **តំលៃបំរុងសំរាប់ការប្រែប្រួលបរិមាណការងារ**

តំលៃបំរុងសំរាប់ការប្រែប្រួលបរិមាណការងារជាការចាត់បញ្ចូលនូវភាគរយប្រាកដមួយនៃការសរុបនូវតំលៃដែលអធិប្បាយខាងលើ ឧទាហរណ៍ 10% នៃការសន្មតនៃកំណើនការងារប្រាកដមួយ ឬក៏ការចំណាយផ្សេងៗដែលអាចនឹងកើតឡើងនៅក្នុងដំណាក់កាលនៃការសាងសង់ ។

8) **តំលៃបំរុងសំរាប់ការប្រែប្រួលនៃតំលៃទីផ្សារ**

តំលៃបំរុងសំរាប់ការប្រែប្រួលនៃតំលៃទីផ្សារជាការសន្មត់តំលៃប្រាកដ ដែលអាចប្រែប្រួលសំរាប់អត្រាប្រាក់រៀល និង ប្រាក់បរទេស (ដុល្លាសហរដ្ឋ) ។

(4) **តំលៃប្រាក់ចរាចរ**

សមាសភាគនីមួយៗនៃតំលៃរបស់គំរោងត្រូវតែផ្តល់ដោយការចូលរួមដូចខាងក្រោម សំរាប់ការវាយតំលៃគំរោង

- តំលៃសំភារៈ (ក្នុងស្រុក បរទេស)
- តំលៃបរិក្ខារ (ក្នុងស្រុក បរទេស)
- តំលៃកំលាំងពលកម្ម (ក្នុងស្រុក)
- តំលៃពលកម្មជំនាញ (ក្នុងស្រុក បរទេស)

សំរាប់ជាឧទាហរណ៍ តំលៃនៃការជីកដីដោយម៉ាស៊ីនបង្ហាញដូចតទៅ :

| សំភារៈ | | បរិក្ខារ | | ពលកម្ម | |
|---|---|---|---|---|---|
| ក្នុងស្រុក | បរទេស | ក្នុងស្រុក | បរទេស | ធម្មតា | ជំនាញ |
| 0.9 % | 17.5 % | 7.6 % | 68.6 % | 0.0 % | 5.3 % |

ការជីកដីដោយម៉ាស៊ីន វាជាការចាំបាច់ណាស់ដែលត្រូវការបរិក្ខារ និង ប្រេងឥន្ធនៈ ព្រមទាំងពលកម្មដែលមានជំនាញ ដូច្នេះការចរាចរប្រាក់ និង តំលៃចូលរួមគឺរក្សាទុកដាច់ដោយឡែក ។ នៅលើការងារដោយឡែក ផ្សេងៗទៀតដូចជាការជីកដីដោយកំលាំងពលកម្មត្រូវបានរក្សាទុកដោយឡែកដូចតទៅ :

| សំភារៈ | | បរិក្ខារ | | ពលកម្ម | |
|---|---|---|---|---|---|
| ក្នុងស្រុក | បរទេស | ក្នុងស្រុក | បរទេស | ធម្មតា | ជំនាញ |
| 0.5 % | 9.5 % | 4.1 % | 37.4% | 45.5 % | 2.9 % |

ក្នុងករណីនេះ កំលាំងពលកម្មធម្មតាតំលៃរបស់វាគ្របក្តាប់ប្រមាណពាក់កណ្តាលនៃតំលៃសរុប ។

តំលៃប្រាក់ចរាចរ និង តំលៃដោយឡែក ជាការកំណត់មួយដោយជំពូកការងារយោងលើតំរូវការ ការងារ ។

(5) **ការចេញប្រាក់ចាយវាយ**

ការចេញប្រាក់ចាយវាយនៃតំលៃគំរោងត្រូវតែកំណត់ យោងលើការអនុវត្តន៍កម្មវិធីរបស់គំរោង ។ តំលៃវិនិយោគដំបូងគួរតែផ្ដល់សំរាប់គំរោងក្នុងរយៈពេលណាមួយ (ឧទាហរណ៍ 5 ឆ្នាំ) ។

(6) **តំលៃប្រតិបត្តិការ និង ការថែទាំ**

តំលៃនៃការងារប្រតិបត្តិការ និង ការថែទាំប្រចាំឆ្នាំនៃសំភារៈបរិក្ខាររបស់គំរោងបូកសរុបជាមួយ ប្រាក់ខែរបស់បុគ្គលិកសំរាប់ការិយាល័យគំរោង បុគ្គលិកនៃសហគមន៍កសិករប្រើប្រាស់ទឹក បុគ្គលិកនៃផ្នែក ទីផ្សារ តំលៃសំភារៈនិងឈ្នួលពលកម្ម សំរាប់ការថែទាំប្រចាំឆ្នាំតំលៃនៃប្រតិបត្តិការ ការជួសជុល ថែទាំ មធ្យោបាយដឹកជញ្ជូន ព្រមទាំងការជួសជុលខ្នាតធំតាមប្រភពគុងត្រារៀងរាល់ប្រាំឆ្នាំម្ដង ។

(7) **តំលៃគ្រឿងបន្លាស់**

សំណង់ខ្លះៗរបស់គំរោងព្រមទាំងបរិក្ខារ មានរយៈកាលសេដ្ឋកិច្ចខ្លីជាងគំរោង និង តំរូវការនូវការផ្លាស់ ប្ដូរក្នុងរយៈពេលដែលសន្មត់ 50 ឆ្នាំនៃជីវិតរបស់គំរោង ។ តារាងជាបន្តបន្ទាប់បង្ហាញពីរយៈកាលជីវិតសេដ្ឋកិច្ច ដែលបានកំណត់នៅក្នុងតំបន់ដែលបានសិក្សានៃផ្នែកខាងលើស្ទឹងស្លាគូ (USP) ។

តារាងរយៈកាលបំលាស់ប្ដូរ

| អធិប្បាយ | រយៈពេលជីវិតសេដ្ឋកិច្ច |
|---|---|
| ការិយាល័យ / បរិក្ខារ | 30 ឆ្នាំ |
| ទ្វារទឹកទាំងអស់ | 25 ឆ្នាំ |
| ដែកបន្ទះ | 10 ឆ្នាំ |
| បរិក្ខារដឹកជញ្ជូន និង ម៉ាស៊ីនភ្លើង | 10 ឆ្នាំ |
| បរិក្ខាររដ្ឋបាល | 8 ឆ្នាំ |
| បរិក្ខារសំរាប់ផ្នែកទីផ្សារ | 8 ឆ្នាំ |
| ទ្វារទឹកឈើ | 5 ឆ្នាំ |